មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ខែធ្នូ ឆ្នាំ២០១៥

## កំណត់ត្រាសង្ខេប

# ស្ត្រីនៅជួរមុខ ៖ ស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្សស្ត្រី នៅកម្ពុជាក្នុងឆ្នាំ២០១៥




ឧបត្ថម្ភដោយ

UN WOMEN
United Nations Entity for Gender Equality
and the Empowerment of Women

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ជាអង្គការមិនមែនរដ្ឋាភិបាល ("អង្គការ") មិនចូលបក្សសម្ព័ន្ធ ឯករាជ្យ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។ ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឲ្យកម្ពុជាក្លាយជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សាដែលប្រជាពលរដ្ឋទទួលបានសិទ្ធិមូលដ្ឋានមានសមភាព និងត្រូវអនុញ្ញាតឲ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានប្រយោជន៍ពីការអភិវឌ្ឍន៍ប្រទេស។ ម.ស.ម.ក ចង់បាននីតិរដ្ឋជាជាងនិទណ្ឌភាព ចង់បានស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំងនិងចង់បានសង្គមពហុនិយមដែលក្នុងនោះ ភាពចម្រុះបែបត្រូវបានទទួលយកនិងសាទរជាជាងការព្រងើយកន្តើយឬដាក់ទណ្ឌកម្ម។ ស្លាកសញ្ញារបស់ ម.ស.ម.ក រំលេចឲ្យឃើញរូបសត្វ ព្រាប ស ហើរចេញពីរង្វង់មូលនៃផ្ទៃពណ៌ខៀវដែលជានិមិត្តរូបនៃការទាមទារសេរីភាពរបស់កម្ពុជា។

កំណត់ត្រាសង្ខេបស្តីពី "ស្ត្រីនៅជួរមុខ ៖ ស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្សស្ត្រីនៅកម្ពុជាក្នុងឆ្នាំ២០១៥" ("កំណត់ត្រាសង្ខេប") គឺជាលទ្ធផលរបស់គម្រោងអ្នកការពារសិទ្ធិមនុស្សស្ត្រី ("គម្រោង") ដែលអនុវត្តន៍ដោយ ម.ស.ម.ក។

## សេចក្តីថ្លែងអំណរគុណ

កំណត់ត្រាសង្ខេបនេះកើតចេញបានក្រោមកិច្ចឧបត្ថម្ភគាំទ្រដោយសប្បុរសអំពីសំណាក់ការិយាល័យភ្នាក់ងារសហប្រជាជាតិលើកកម្ពស់យេនឌ័រនិងផ្តល់ភាពអង់អាចដល់ស្ត្រីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា("UN Women")។ ខ្លឹមសារក្នុងកំណត់ត្រាសង្ខេបនេះគឺជាការទទួលខុសត្រូវរបស់ ម.ស.ម.ក និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គការ UN Women នោះទេ។ ម.ស.ម.ក សូមសម្តែងនូវការកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះអ្នកដែលបានចូលរួមក្នុងការស្រាវជ្រាវនេះ ដើម្បីរួមចំណែកធ្វើឲ្យកំណត់ត្រាសង្ខេបនេះប្រកបដោយអត្ថន័យ។

## សំណួរ និងមតិឆ្លើយតប

កំណត់ត្រាសង្ខេបនេះ និងការបោះពុម្ពផ្សាយផ្សេងៗទៀតរបស់ ម.ស.ម.ក អាចរកបានតាមរយៈវេបសាយ www.cchrcambodia.org និងគេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជាដែលទទួលបានពានរង្វាន់បង្កើតឡើងដោយ ម.ស.ម.ក តាមរយៈ www.sithi.org

ប្រសិនបើអ្នកមានសំណួរ ឬត្រូវការព័ត៌មានបន្ថែមអំពីកំណត់ត្រាសង្ខេបនេះ ឬមានបំណងចង់ផ្តល់មតិឆ្លើយតប សូមផ្ញើសារអេឡិចត្រូនិចមកកាន់ ម.ស.ម.ក តាមរយៈអ៊ីម៉ែល info@cchrcambodia.org ឬទាក់ទងមក ម.ស.ម.ក តាមរយៈអាសយដ្ឋាន ៖

ផ្ទះ ៧៩៨ ផ្លូវ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា

ទូរសព្ទ ៖ + ៨៥៥ (០)២៣ ៧២ ៦៩ ០១

ទូរសារ ៖ + ៨៥៥ (០)២៣ ៧២ ៦៩ ០២

គេហទំព័រ ៖ www.cchrcambodia.org

# មាតិកា


មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ........................................ i
សេចក្ដីថ្លែងអំណរគុណ ........................................ i
ពាក្យកាត់ ........................................ iv
ខ្លឹមសារសង្ខេប ........................................ 1
១. ក្របខ័ណ្ឌច្បាប់ ........................................ 10
១.១ ក្របខ័ណ្ឌច្បាប់អន្តរជាតិ ........................................ 10
១.២ ក្របខ័ណ្ឌច្បាប់ថ្នាក់តំបន់ ........................................ 15
១.៣ ក្របខ័ណ្ឌច្បាប់ជាតិ ........................................ 17
២. ស្ថានភាពរបស់ស្ត្រីនៅកម្ពុជា ........................................ 21
៣. បទពិសោធន៍របស់អ្នកការពារសិទ្ធិមនុស្សស្ត្រីដែលទទួលបានការគាំទ្រពីគម្រោង ...26
៣.១ ករណីសិក្សា ........................................ 27
៣.២ ចម្រៀង ........................................ 38
៤. សេចក្ដីសន្និដ្ឋាននិងអនុសាសន៍ ........................................ 40

# ពាក្យកាត់

| | |
|---|---|
| អាស៊ាន | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| កំណត់ត្រាសង្ខេប | ស្ត្រីនៅជួរមុខ ៖ ស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្សស្ត្រីនៅកម្ពុជាក្នុងឆ្នាំ២០១៥ |
| កម្ពុជា | ព្រះរាជាណាចក្រកម្ពុជា |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| គណៈកម្មាធិការ | គណៈកម្មាធិការការពារសេរីភាពមូលដ្ឋាន |
| រដ្ឋធម្មនុញ្ញ | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ (វិសោធនកម្ម ) |
| ស៊ី ដ | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី |
| សង្គមស៊ីវិល | អង្គការសង្គមស៊ីវិល |
| សហភាពអ៊ឺរ៉ុប | សហភាពអ៊ឺរ៉ុប |
| អ.ក.ស.ម | អ្នកការពារសិទ្ធិមនុស្ស |
| ក.ស.អ.ព.ន | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| អង្គការ | អង្គការមិនមែនរដ្ឋាភិបាល |
| រដ្ឋាភិបាល | រាជរដ្ឋាភិបាលកម្ពុជា |
| អ្នករាយការណ៍ពិសេស | អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្ស |
| ធីភីអូ | អង្គការចិត្តសង្គម អន្តរវប្បធម៌ |
| ស.ប.ស.ស | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធមនុស្ស |
| ចក្រភពអង់គ្លេស | ចក្រភពអង់គ្លេស |
| UN Women | ការិយាល័យភ្នាក់ងារសហប្រជាជាតិលើកកម្ពស់យេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា |

| | |
|---|---|
| យូភីអ | ការត្រួតពិនិត្យជាសាកលតាមពេលវេលាកំណត់ |
| អ.ក.ស.ម.ស | អ្នកការពារសិទ្ធិមនុស្សស្ត្រី |

# ខ្លឹមសារសង្ខេប

*«ធ្វើជាអ្នកការពារសិទ្ធិមនុស្សស្ត្រីមានន័យថាខ្លួនជាអ្នកចេញមុខប្រឈមនឹងការគំរាមកំហែងដោយសារតែខ្លួនជាស្ត្រី និងដោយសារការតស៊ូដើម្បីការពារ និងលើកកម្ពស់សិទ្ធិមនុស្ស។»*

ដោយ មីសែល ហ្វ័ស្ត អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស ខែកក្កដា ឆ្នាំ ២០១៥[1]

ខណៈដែលការបោះឆ្នោតថ្នាក់ជាតិសម្រាប់ឆ្នាំ២០១៧ និងឆ្នាំ២០១៨ កាន់តែខិតជិតមកដល់ ការរំលោភសិទ្ធិមនុស្សជាច្រើន ការរួមតូចនៃលំហលទ្ធិប្រជាធិបតេយ្យ និងការគាបសង្កត់ជាលក្ខណៈប្រព័ន្ធលើសំឡេងជំទាស់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា («រដ្ឋាភិបាល»)កំពុងតែបង្ហាញពីបរិយាកាសនយោបាយនាពេលបច្ចុប្បន្នក្នុងព្រះរាជាណាចក្រកម្ពុជា[2](«កម្ពុជា»)។ នៅក្នុងបរិបទនេះ សកម្មជន និងប្រធានសហគមន៍ដែលក្រោកឈរការពារសិទ្ធិរបស់ប្រជាពលរដ្ឋកំពុងប្រឈម ជាពិសេសនឹងការឃាយឺតាមប្រព័ន្ធតុលាការដូចជាការចាប់ខ្លួនតាមអំពើចិត្ត ការឃុំខ្លួន និងការផ្តន្ទាទោសដោយមិនត្រឹមត្រូវ ព្រមទាំងអំពើហិង្សាលើរូបរាងកាយ ឬរហូតដល់បាត់បង់ជីវិតជាដើម។ ជាងនេះទៅទៀត យោងតាមបទពិសោធន៍ជាច្រើនដែល ម.ស.ម.ក បានធ្វើការជាមួយអ្នកការពារសិទ្ធិមនុស្ស ("អ.ក.ស.ម") បង្ហាញថា អ.ក.ស.ម យ៉ាងច្រើននៅកម្ពុជាគឺជាស្ត្រី ប៉ុន្តែចក្ខុវិស័យយេនឌ័រក្នុងការងាររបស់ពួកគេតែងតែត្រូវបានបំភ្លេច។ នៅកម្ពុជាដែលជាប្រទេសមានអំពើហិង្សាដែល

[1]មហាសន្និបាតអង្គការសហប្រជាជាតិ ស្ថានភាពអ្នកការពារសិទ្ធិមនុស្ស ៖ កំណត់សម្គាល់របស់អគ្គលេខាធិការ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ A/៧០/២១៧ អាចរកបានតាមរយៈ ៖ http://www.refworld.org/docid/55f288724.html [ដកស្រង់នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៥]

[2]សម្រាប់ការពិនិត្យឡើងវិញលម្អិតពីការគំរាមកំហែងបច្ចុប្បន្នលើលទ្ធិប្រជាធិបតេយ្យសូមមើល "កម្ពុជា ៖ លទ្ធិប្រជាធិបតេយ្យរងការគំរាមកំហែង" ម.ស.ម.ក ខែកញ្ញា ឆ្នាំ២០១៥ អាចរកបានតាមរយៈ ៖<http://cchrcambodia.org/index_old.php?url=media/media.php&p=analysis_detail.php&anid=70&id=5>

ផ្អែកលើវិសមភាពយេនឌ័រ និងការរើសអើងនៅតែកើតមានច្រើន ហើយស្ថានភាពរបស់ អ.ក.ស.ម.ស កំពុងប្រឈមនឹងបញ្ហាជាច្រើន។

ក្នុងនាមជាប្រធានសហគមន៍ សកម្មជនសង្គមស៊ីវិល អ.ក.ស.ម.ស កម្ពុជាដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ ពង្រឹង និងការពារសិទ្ធិមនុស្ស។ ប៉ុន្តែអ្នកទាំងនោះតែងប្រឈមនឹងការគំរាមកំហែង ការបៀតបៀននិងអសន្តិសុខក្នុងពេលបំពេញការងាររបស់ខ្លួន។ ការរំលោភសិទ្ធិមនុស្សលើ អ.ក.ស.ម.ស កើតមានជាច្រើនទម្រង់ដូចជា ការយាយីតាមផ្លូវតុលាការ ការចាប់ខ្លួនតាមអំពើចិត្ត ការឃុំខ្លួនដោយខុសច្បាប់ ការកាត់ទោសធ្ងន់ធ្ងរលើបទល្មើសតូចតាច និងការរើសអើងដោយផ្អែកលើយេនឌ័រ និងអំពើហិង្សាដោយផ្អែកលើយេនឌ័រចាក់ឫសនាំឲ្យមានការអនុវត្តនិងបទដ្ឋានសង្គមមានលក្ខណៈរើសអើង។ អំពើហិង្សាលើស្ត្រីដែលកើតចេញពីប្រពៃណីឲ្យតម្លៃយេនឌ័រដែលកំណត់ថាស្ត្រីមានឋានៈទាបនិងអំណាចតិចជាងបុរសនៅតែកើតមានជាទូទៅក្នុងប្រទេសកម្ពុជា។ ទោះបីជាមានការការពារក្នុងច្បាប់ជាតិនិងច្បាប់អន្តរជាតិ ក៏អំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ អំពើហិង្សាផ្លូវភេទ ការបៀតបៀន និងការកេងប្រវ័ញ្ចផ្លូវភេទនៅតែកើតមានច្រើន។ ការរំលោភបំពានទាំងនេះតែងតែជាករណីនិទណ្ឌភាព។ ក្រៅពីនេះ អ.ក.ស.ម.ស តែងតែរងសម្ពាធដោយបង្ខំឲ្យចុះហត្ថលេខាលើឯកសារដែលបញ្ជាក់ថានឹងមិនចូលរួមក្នុងការតវ៉ានៅថ្ងៃខាងមុខ។ នេះជាសកម្មភាពដែលគួរឲ្យបារម្ភហើយកើតមានច្រើននៅកម្ពុជាដូច ម.ស.ម.ក បានលម្អិតនៅក្នុងកំណត់ត្រាសង្ខេបពីមុនដែលមានចំណងជើងថា *"ការដោះលែងដោយមានលក្ខខណ្ឌលើ អ.ក.ស.ម បានរំលោភលើសិទ្ធិជាមូលដ្ឋាននៃសេរីភាពខាងការបញ្ចេញមតិនិងជួបប្រជុំ"*។[3] អ.ក.ស.ម.ស មួយចំនួនបានរាយការណ៍ថាដោយសារតែអំពើ

---

[3] "ការដោះលែងដោយមានលក្ខខណ្ឌលើអ្នកការពារសិទ្ធិមនុស្សបានរំលោភលើសិទ្ធិជាមូលដ្ឋាននៃសេរីភាពខាងការបញ្ចេញមតិ និងជួបប្រជុំ" ៖http://www.cchrcambodia.org/admin/media/analysis/analysis/english/Conditional_Release_of_Human_Rights_Defenders_Violates_Fundamental_Rights_to_Freedoms_of_Expression_and_Assembly_en.pdf

ហិង្សា ការគំរាមកំហែង និងការបៀតបៀនដែលពួកគាត់ធ្លាប់ឆ្លងកាត់បានធ្វើឲ្យពួកគាត់ប្រឈមនឹងភាពតានតឹងផ្លូវចិត្ត និងជំងឺថប់បារម្ភកម្រិតខ្ពស់។

ទោះបីជាតាមគោលការណ៍ អ.ក.ស.ម.ស ត្រូវបានការពារក្រោមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិដូចជា កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (“ក.ស.ស.ព.ន”) ប៉ុន្តែ អ.ក.ស.ម ជាច្រើននៅកម្ពុជា នៅតែប្រឈមនឹងគ្រោះថ្នាក់ដ៏ច្រើនអនេក។ ភាពស្ទាក់ស្ទើររបស់រដ្ឋាភិបាលក្នុងការការពារ អ.ក.ស.ម និងតួនាទីដ៏សកម្មរបស់រដ្ឋាភិបាលក្នុងការរឹតត្បិតលើសិទ្ធិរបស់ពួកគេបានបង្ហាញពីការរំលោភកាតព្វកិច្ចរបស់រដ្ឋក្នុងការគោរព ការពារ និងគោរពសិទ្ធិមនុស្ស ហើយថែមទាំងរឹតត្បិតធ្ងន់ធ្ងរដល់បរិយាកាសបំពេញការងាររបស់ អ.ក.ស.ម។

កំណត់ត្រាសង្ខេបនេះមានគោលបំណងផ្តល់ទិដ្ឋភាពរួមស្តីពី ស្ថានភាពរបស់អ.ក.ស.ម.ស នៅកម្ពុជាក្នុងឆ្នាំ២០១៥ ដោយផ្អែកតាមបទពិសោធន៍នៃគម្រោងអ្នកការពារសិទ្ធិមនុស្សស្ត្រីរបស់ ម.ស.ម.ក (“គម្រោង”) ក្នុងរយៈពេលពាក់កណ្តាលឆ្នាំចុងក្រោយនៃឆ្នាំ២០១៥។ គម្រោងនេះគឺជាគម្រោងផ្តោតលើវិស័យយេនឌ័រដែលបន្តពីគម្រោង អ.ក.ស.ម ពីមុនរបស់ ម.ស.ម.ក[4] និងជាគម្រោងដែលផ្តោតលើ អ.ក.ស.ម.ស ដំបូងនៅកម្ពុជា។ ព័ត៌មានដែលបង្ហាញក្នុងកំណត់ត្រាសង្ខេបនេះគឺយោងទៅលើទិន្នន័យដែលប្រមូលបានដោយម.ស.ម.ក ក្នុងការអនុវត្តគម្រោង អ.ក.ស.ម.ស ដែលជាផ្នែកមួយនៃគម្រោងការពារសេរីភាពមូលដ្ឋានរបស់ ម.ស.ម.ក[5]ដែលផ្តល់ការគាំទ្រដល់ អ.ក.ស.ម ដែលទទួលរងការគំរាមកំហែង និងលើកកម្ពស់សិទ្ធិរបស់ អ.ក.ស.ម ក្នុងគោលបំណងឲ្យមានការផ្លាស់ប្តូរជា

---

[4]សម្រាប់គោលបំណងនៃកំណត់ត្រាសង្ខេបនេះ អ្នកការពារសិទ្ធិមនុស្សស្ត្រីគឺជាស្ត្រីគ្រប់វ័យ ដែលចូលរួមក្នុងការការពារសិទ្ធិមនុស្ស។

[5]គម្រោងការពារសេរីភាពមូលដ្ឋាន (“គម្រោង”) មានបំណងដោះស្រាយការរិតត្បិតជាបន្តបន្ទាប់លើសេរីភាពមូលដ្ឋានដូចជា សេរីភាពបង្កើតសមាគម សេរីភាពជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិក្នុងព្រះរាជាណាចក្រកម្ពុជា (“កម្ពុជា”) ជាពិសេសដោយអ្នកការពារសិទ្ធិមនុស្ស (“អ.ក.ស.ម”) ប្រជានសហជីព និងកម្មករនិយោជិត សកម្មជនសហគមន៍/តាមអ៊ីនធឺណែត/នយោបាយ អ្នកកាសែត និងអ្នកតវ៉ាដោយសន្តិវិធី។

រដ្ឋមាននូវគោលនយោបាយរបស់រដ្ឋាភិបាល ការគោរព និងការអនុវត្តតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។ ដូចមានការពន្យល់ខាងក្រោម គម្រោងមានគោលបំណងផ្តល់ការការពារទាំងផ្លូវច្បាប់ និងផ្លូវចិត្តដល់ស្ត្រីដែលប្រឈមនឹងហានិភ័យដោយសារទទួលរងការគំរាមកំហែង និងការបៀតបៀនដោយសារភាពសកម្មរបស់ខ្លួនក្នុងនាមជា អ.ក.ស.ម.ស ។

ផ្នែកទីមួយនៃកំណត់ត្រាសង្ខេបនេះបង្ហាញពីក្របខ័ណ្ឌច្បាប់សម្រាប់ការពារ អ.ក.ស.ម.ស នៅថ្នាក់អន្តរជាតិ ថ្នាក់តំបន់ និងថ្នាក់ជាតិ ព្រមទាំងរំលេចនូវកាតព្វកិច្ចរបស់រដ្ឋាភិបាលដើម្បីការពារ អ.ក.ស.ម.ស ។ នៅផ្នែកទី២ និងទី៣ នឹងវិភាគទៅលើស្ថានភាពរបស់ស្ត្រីនៅកម្ពុជា និងទស្សនវិស័យលើផ្នែកចិត្តសាស្ត្រសង្គមលើការងាររបស់ អ.ក.ស.ម.ស ។ ផ្នែកទី៤ បង្ហាញពីរឿងរ៉ាវរបស់ អ.ក.ស.ម.ស មួយចំនួនដែលទទួលបានការគាំទ្រពីគម្រោងនេះ។ ចុងក្រោយនៃកំណត់ត្រាសង្ខេបនេះនឹងធ្វើសេចក្តីសន្និដ្ឋានភ្ជាប់មកជាមួយនូវអនុសាសន៍ដាក់ជូនរដ្ឋាភិបាលកម្ពុជា និងតុលាការដើម្បីលើកកម្ពស់ស្ថានភាព អ.ក.ស.ម.ស នៅកម្ពុជា។

កាលពីខែមេសា ឆ្នាំ២០១៥ ម.ស.ម.ក បានចេញផ្សាយកំណត់ត្រាសង្ខេបមួយ[6] ដែលវាយតម្លៃស្ថានភាពរបស់ អ.ក.ស.ម នៅកម្ពុជារួមមាន ការរឹតត្បិតលើសេរីភាពមូលដ្ឋាននិងការឃាយឃីគ្រប់ទម្រង់។ ក្នុងឱកាសនេះ ម.ស.ម.ក សូមអំពាវនាវឲ្យរដ្ឋាភិបាលកម្ពុជា និងតុលាការអនុវត្តតាមអនុសាសន៍ដូចខាងក្រោម ៖

- *ធានាឲ្យមានការស៊ើបអង្កេតបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធិភាព ហើយផ្តន្ទាទោសជនដៃដល់ដោយស្លាប័នឯករាជ្យ និងមិនលម្អៀង ធ្វើរបាយការណ៍អំពីការប្រើប្រាស់កម្លាំងហួសប្រមាណពីសំណាក់មន្ត្រីអនុវត្តច្បាប់ និងកងកម្លាំងសន្តិសុខឯកជនដែលអាជ្ញាធរមូលដ្ឋានបានជួលមកបម្រើការ ព្រមទាំងដាក់បង្ហាញលទ្ធផលនោះជាសាធារណៈ។*

[6]ស្ថានភាពរបស់អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០១៤ អាចរកបានតាមរយៈ http://cchrcambodia.org/admin/media/analysis/analysis/english/2015_04_01_CCHR_BN_The_Situation_of_HRDs_in_Cambodia_in_2014_(ENG).pdf

- ជានាផ្តល់សំណងសមរម្យដល់ជនរងគ្រោះ និងជានាថារាល់ករណីរំលោភបំពាន និងអំពើហិង្សាប្រឆាំងនឹងអ្នកសារព័ត៌មាន សកម្មជននយោបាយ អ្នកនយោបាយគណបក្សជំទាស់ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល សមាជិកសហជីព និងអ្នកការពារសិទ្ធិមនុស្សផ្សេងទៀតត្រូវបានស៊ើបអង្កេតត្រឹមត្រូវ ហើយជនដៃដល់ត្រូវបាននាំយកមកផ្តន្ទាទោសដោយមិនគិតពីឋានៈរបស់ជននោះ។
- ជានាការគោរពសិទ្ធិសេរីភាពក្នុងការជួបប្រជុំ ហើយបញ្ឈប់ជាផ្លូវការនូវការហាមប្រាមតាមអំពើចិត្តទាំងស្រុងចំពោះការជួបប្រជុំជាសាធារណៈ។
- បញ្ឈប់នូវការអនុវត្តដែលបង្ខំឲ្យ អ.ក.ស.ម ចុះហត្ថលេខាលើកិច្ចសន្យា ដែលមានការរឹតត្បិតដល់សិទ្ធិរបស់ពួកគេដើម្បីជាថ្នូរទៅនឹងការដោះលែង ឬចៀសវាងការចោទប្រកាន់ព្រមទាំងលុបចោលនូវលិខិតទាំងឡាយណាដែលបានចុះហត្ថលេខានាពេលកន្លងមក។
- អនុវត្តជាបន្ទាន់នូវការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិស្របទៅតាមគោលការណ៍ទីក្រុងប៉ារីស[7] ។
- បញ្ឈប់ការយាយីតាមប្រព័ន្ធតុលាការទៅលើ អ.ក.ស.ម សកម្មជននយោបាយ និងអ្នកនយោបាយបក្សជំទាស់ ព្រមទាំងដោះលែងជាបន្ទាន់ដោយគ្មានលក្ខខណ្ឌដល់អ្នកកំពុងជាប់ឃុំដែលត្រូវបានចោទប្រកាន់ ផ្តន្ទាទោសដោយសារហេតុផលនយោបាយ។
- ឆ្លើយតបជាវិជ្ជមានចំពោះសំណើរបស់អ្នករាយការណ៍ពិសេសអំពីស្ថានភាព អ.ក.ស.ម នៅក្នុងដំណើរទស្សនកិច្ចផ្លូវរដ្ឋ (នៅឆ្នាំ២០១២ អ្នករាយការណ៍ពិសេសបានសរសេរសំណើមកកាន់រដ្ឋាភិបាលដើម្បីមកធ្វើទស្សនកិច្ចផ្លូវរដ្ឋនៅកម្ពុជា[8] )។

---

[7]គោលការណ៍ក្រុងប៉ារីស គឺជាកម្រងបទដ្ឋានអន្តរជាតិដែលជះឥទ្ធិពល និងណែនាំការងាររបស់ស្ថាប័នសិទ្ធិមនុស្សជាតិ។ គោលការណ៍ទាំងនេះត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ សេចក្តីសម្រេចលេខ ៤៨/១៣៤។
http://www.ohchr.org/EN/ProfessionalInterest/Pages/StatusOfNationalInstitutions.aspx

ម.ស.ម.ក ក៏សូមរំលឹកឡើងវិញពីអនុសាសន៍ទាំងនោះ និងផ្តល់អនុសាសន៍បន្ថែមដល់រដ្ឋាភិបាលកម្ពុជាជាពិសេសពាក់ព័ន្ធនឹង អ.ក.ស.ម.ស ដែលរួមមាន ៖

- *ទទួលស្គាល់នូវតម្រូវការការពារជាក់លាក់របស់ក្រុម អ.ក.ស.ម ដូចជា អ.ក.ស.ម.សដែលពាក់ព័ន្ធនឹងបញ្ហាក្នុងជីវិតឯកជនរបស់ពួកគេ។*
- *ជំរុញឲ្យមានកម្មវិធីជាក់លាក់ដែលប្រឆាំងទៅនឹងការរើសអើងភេទចំពោះ អ.ក.ស.ម.ស។*
- *ផ្តល់ការទទួលស្គាល់ជាផ្លូវច្បាប់ និងនយោបាយដល់ការងាររបស់អ.ក.ស.ម.ស។*
- *មន្ត្រីសាធារណៈត្រូវជៀសវាងក្នុងការប្រើប្រាស់ភាសាអសុរោះ ឬរើសអើងទៅលើ អ.ក.ស.ម.ស និងស្ត្រីទូទៅ និងគួរដឹកនាំការលើកកម្ពស់សិទ្ធិ និងសេចក្តីថ្លៃថ្នូរបស់ អ.ក.ស.ម.ស។*
- *បង្កើតយន្តការនិងកម្មវិធីការពារថ្នាក់ជាតិសម្រាប់ អ.ក.ស.ម.ស ដែលប្រឈមនឹងហានិភ័យ។*
- *ដាក់បញ្ចូលក្នុងកម្មវិធីអប់រំដែលផ្តោតលើការលុបបំបាត់ឫសគល់រចនាសម្ព័ន្ធនៃអំពើហិង្សា និងការរើសអើងប្រឆាំងនឹងស្ត្រី និងវិសមភាពសេដ្ឋកិច្ចសង្គមដោយផ្អែកលើយេនឌ័រ។*

ក្រៅពីនេះ ម.ស.ម.ក ក៏សូមជូនអនុសាសន៍មួយចំនួនដល់អង្គការសង្គមស៊ីវិល និងស្ថាប័នអន្តរជាតិដែលធ្វើការជាមួយស្ត្រី និង អ.ក.ស.ម នៅកម្ពុជាដូចខាងក្រោម ៖

- *លើកកម្ពស់ការបញ្ជ្រាបយេនឌ័រតាមស្ថាប័នដោយបង្កើតគោលនយោបាយសមភាពយេនឌ័រ ដែលអនុវត្តចំពោះកម្មវិធី និងនីតិវិធីផ្ទៃក្នុង។*
- *រៀបចំវគ្គបណ្តុះបណ្តាលអំពីវិញ្ញោចយេនឌ័រសម្រាប់បុគ្គលិកទាំងអស់ដើម្បីបង្កើនការយល់ដឹងពីបញ្ហាជួបប្រទះរបស់អ.ក.ស.ម.ស និងស្ត្រីទូទៅនៅកម្ពុជា។*

---

[8]អង្គការសហប្រជាជាតិ ៖ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស "ទស្សនកិច្ចផ្លូវរដ្ឋ" http://goo.gl/Z1SD0r

- *ផ្តល់វគ្គបណ្តុះបណ្តាលអំពីវិញ្ញាចយេនឌ័រសម្រាប់មេធាវីដែលការពារក្តីឲ្យ អ.ក.ស.ម.ស។*
- *ណែនាំពីទស្សនវិស័យយេនឌ័រដល់ការងារតស៊ូមតិដែលអនុវត្តក្នុងនាម អ.ក.ស.ម ។*

កំណត់ត្រាសង្ខេបនេះធ្វើឡើងដោយ ម.ស.ម.ក ដែលជាអង្គការមិនមែនរដ្ឋាភិបាល មិនមាននិន្នាការនយោបាយ ឯករាជ្យ ឈានមុខមួយដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

គម្រោង អ.ក.ស.ម.ស របស់ ម.ស.ម.ក មានបំណងពង្រឹងសិទ្ធិអំណាច និងការពារ អ.ក.ស.ម.ស នៅកម្ពុជាដោយសហការជាមួយអង្គការចិត្តសង្គម អន្តរវប្បធម៌ (ធីភីអូ) និងអង្គការ UN Women គម្រោងបានផ្តល់ជំនួយផ្លូវច្បាប់ មនុស្សធម៌ និងចិត្តសង្គមដល់ អ.ក.ស.ម.ស ដែលប្រឈមនឹងអំពើហិង្សា ការបៀតបៀន និងការគំរាមកំហែងដោយសារការងាររបស់ពួកគេ។

គម្រោងនេះអនុវត្តសកម្មភាពជាច្រើនក្នុងគោលបំណងដើម្បីពង្រឹងស្ថានភាពរបស់ អ.ក.ស.ម.ស និងផ្តល់ការការពារដើម្បីឲ្យពួកគេបន្តបំពេញការងារសំខាន់ៗជំនួសមុខឲ្យសហគមន៍ទាំងមូល។ ការគាំទ្រជាលក្ខណៈបុគ្គលដូចជា ជំនួយផ្លូវច្បាប់ មនុស្សធម៌ និង/ឬជំនួយបន្ទាន់ដូចជា ផ្ទះសុវត្ថិភាព អាហារ និងការផ្តល់សម្ភារៈ និងការថែទាំផ្នែកវេជ្ជសាស្ត្រ ត្រូវបានផ្តល់ឲ្យ អ.ក.ស.ម.ស ដែលឆ្លងកាត់ ឬប្រឈមនឹងហានិភ័យដោយសារតែការងាររបស់ពួកគេ។ គោលបំណងនៃការគាំទ្រនេះ គឺដើម្បីឲ្យ អ.ក.ស.ម.ស ប្រឈម និងទប់ទល់នឹងការរំលោភបំពានលើសិទ្ធិមនុស្សរបស់ពួកគេ។ ម្យ៉ាងវិញទៀត ជំនួយផ្នែកផ្លូវ

ចិត្តត្រូវបានផ្តល់ដល់ករណីមួយចំនួនដើម្បីកាត់បន្ថយផលប៉ះពាល់ពីការប៉ះទង្គិចផ្លូវចិត្ត ធ្ងន់ធ្ងរ។ ករណីទាំងនេះនឹងបង្ហាញលម្អិតក្នុងផ្នែកបន្តបន្ទាប់នៃកំណាត់ត្រាសង្ខេបនេះ[9]។

ដើម្បីធានាការការពារប្រកបដោយប្រសិទ្ធភាពនិងស្របច្បាប់លើបញ្ហាយេនឌ័រ ដល់ អ.ក.ស.ម.ស ម.ស.ម.ក បានរៀបចំវគ្គបណ្តុះបណ្តាលរយៈពេលពីរថ្ងៃសម្រាប់មេធាវីជាប់កិច្ចសន្យាកាលពីខែកញ្ញា។ តាមរយៈកិច្ចសហការជាមួយអង្គការចិត្តសង្គម អន្តរវប្បធម៌ ក្រុមមេធាវីរបស់ ម.ស.ម.ក បានកើនឡើងនូវការយល់ដឹងពីតម្រូវការ និងសិទ្ធិរបស់ អ.ក.ស.ម.ស ព្រមទាំងផលប៉ះពាល់ផ្លូវចិត្តដោយសារអំពើហិង្សា ការបៀតបៀន និងការប៉ះទង្គិចផ្លូវចិត្ត។ កាលពីថ្ងៃទី១៧ ដល់ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៥ គម្រោងបានរៀបចំវគ្គបណ្តុះបណ្តាលដែលសហការជាមួយអង្គការចិត្តសង្គម អន្តរវប្បធម៌ និងអង្គការ UN Women ក្រោមប្រធានបទស្តីពី "ការបណ្តុះបណ្តាលស្តីពីការតស៊ូមតិ និងសុខភាពផ្លូវចិត្តសម្រាប់ អ.ក.ស.ម.ស" ក្នុងគោលបំណងបណ្តុះបណ្តាល អ.ក.ស.ម.ស អំពីយុទ្ធសាស្ត្រតស៊ូមតិ និងរបៀបឆ្លើយតបនិងគ្រប់គ្រងបញ្ហាសុខភាពផ្លូវចិត្តដែលអាចបណ្តាលមកពីសកម្មភាពរបស់ពួកគេក្នុងនាមជា អ.ក.ស.ម.ស ។

> *"ខ្ញុំកាន់តែមានភាពក្លាហាន និងប្តេជ្ញាចិត្តក្នុងការដោះស្រាយបញ្ហារបស់ខ្ញុំ (ចាប់តាំងពីការទទួលជំនួយពីគម្រោង អ.ក.ស.ម.ស)។ ក្រៅពីនេះ ខ្ញុំកំពុងមើលថែខ្លួនឯងទោះបីជាមានបញ្ហាខាងក្រៅកើតឡើងចំពោះខ្ញុំក៏ដោយ"។*

ដោយ អ.ក.ស.ម.ស (វគ្គបណ្តុះបណ្តាលសុខភាពផ្លូវចិត្ត)

> *"ក្នុងនាមជាមេធាវី ខ្ញុំត្រូវដឹង និងយល់ពីស្ថានភាពផ្លូវចិត្ត និងចិត្តគំនិតកូនក្តីរបស់ខ្ញុំពាក់ព័ន្ធនឹងការការពារជាជាងត្រឹមតែបញ្ហាផ្លូវច្បាប់។ ការណ៍*

---

[9]ករណីបុគ្គលដែលទទួលការគាំទ្រផ្នែកចិត្តសាស្ត្រមិនមានបញ្ជាក់លម្អិតឡើយ ដើម្បីធានានូវឯកជនភាពរបស់បុគ្គល។

*នេះអាចឲ្យខ្ញុំផ្តល់ការណែនាំផ្លូវច្បាប់ដល់ពួកគេកាន់តែមានប្រសិទ្ធភាព និងបញ្ចៀសការភ័ន្តច្រឡំក្នុងកិច្ចពិភាក្សា រួមទាំងក្នុងដំណាក់កាលការពារក្តីផងដែរ។*

ដោយមេធាវីជាប់កិច្ចសន្យារបស់ ម.ស.ម.ក (បន្ទាប់ពីទទួលបានការបណ្តុះណ្តាលស្តីពី អ.ក.ស.ម.ស)។

# ១. ក្របខ័ណ្ឌច្បាប់

## ១.១ ក្របខ័ណ្ឌច្បាប់អន្តរជាតិ

សិទ្ធិរបស់ស្ត្រីក្នុងការចូលរួមជាសាធារណៈក្នុងប្រទេសរបស់ខ្លួន ដែលរួមបញ្ចូលទាំងការលើកកម្ពស់ និងការពារសិទ្ធិមនុស្សសុទ្ធតែមានចែងក្នុងសន្ធិសញ្ញា និងសេចក្តីប្រកាសអន្តរជាតិជាច្រើនស្តីពីសិទ្ធិមនុស្ស។ មាត្រា ២ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស («ស.ប.ស.ស»)[10]បានចែងថាមនុស្សគ្រប់រូបទទួលបានការធានានូវសិទ្ធិរបស់ខ្លួនរួមមានដូចជា សិទ្ធិសេរីភាពខាងការបញ្ចេញមតិ ការជួបប្រជុំ និងចូលរួមក្នុងកិច្ចការសាធារណៈ។ ទន្ទឹមនឹងនេះ ក.ស.អ.ព.ន[11]បានចែងពីកាតព្វកិច្ចរបស់រដ្ឋក្នុងការ "*ធានាសិទ្ធិស្មើភាពរបស់បុរស និងស្ត្រីក្នុងការទទួលបានសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយទាំងអស់ដែលមានចែងក្នុងកតិកាសញ្ញានេះ។*

អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី[12](«ស៊ីដ») គឺជាលិខិតុបករណ៍ចងកាតព្វកិច្ចក្រោមច្បាប់កម្ពុជា និងបានប្រកាសពីគោលបំណងលើកកម្ពស់សិទ្ធិស្ត្រីនិងសមភាពយេនឌ័រ។ ប្រទេសចំនួន ១៨៩ រួមទាំងកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញានេះ។ អនុសញ្ញានេះថ្កោលទោសរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី និងអំពាវនាវឲ្យរដ្ឋភាគីទាំងអស់ចាត់វិធានការសមស្របក្នុងការលុបបំបាត់ការរើស

---

[10]មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ២១៧ A (III) អាចរកបានតាម: http://www.refworld.org/docid/3ae6b3712c.html

[11] មហាសន្និបាតអង្គការសហប្រជាជាតិ ៖ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ កម្រងឯកសារសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ លេខ ៩៩៩ ទំព័រ ១៧១ អាចរកបានតាមរយៈ ៖ http://www.refworld.org/docid/3ae6b3aa0.html

[12]មហាសន្និបាតអង្គការសហប្រជាជាតិ ៖ អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩ កម្រងឯកសារសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ លេខ ១២៤៩ ទំព័រ ១៣ អាចរកបានតាមរយៈ ៖ http://www.refworld.org/docid/3ae6b3970.html

អើងលើយេនឌ័រនៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាតិ។ មាត្រា ៧ នៃអនុសញ្ញា ស៊ី ដ តម្រូវឲ្យរដ្ឋភាគី *"ចាត់វិធានការសមស្របទាំងអស់ក្នុងការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីក្នុងជីវភាពនយោបាយនិងកិច្ចការសាធារណៈរបស់រដ្ឋ និងជាពិសេស [...] ធានាថាស្ត្រីមានសិទ្ធិស្មើគ្នានឹងបុរស [...] ដើម្បីចូលរួមក្នុងអង្គការមិនមែនរដ្ឋាភិបាល និងសមាគមពាក់ព័ន្ធនឹងកិច្ចការសាធារណៈ និងជីវភាពនយោបាយរបស់រដ្ឋ។*

លើសពីនេះទៅទៀត នៅឆ្នាំ២០១០ កម្ពុជាបានផ្តល់សច្ចាប័នដល់ពិធីសារបន្ថែមទី១ នៃអនុសញ្ញា ស៊ី-ដ[13] ដែលអនុញ្ញាតឲ្យគណៈកម្មាធិការស្តីពី ស៊ី ដ ទទួលពាក្យបណ្តឹងពីបុគ្គល ឬស៊ើបអង្កេតពី *"ការរំលោភបំពានធ្ងន់ធ្ងរ ឬជាប្រព័ន្ធ"* លើអនុសញ្ញានេះ។

ជាងនេះទៅទៀត ក៏មានយន្តការជំនាញដែលត្រូវបានបង្កើតឡើងដើម្បីផ្តល់ការការពារសិទ្ធិរបស់បុគ្គល និងស្ថាប័នដែលកំពុងការពារសិទ្ធិមនុស្ស។ សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពី អ.ក.ស.ម[14]គឺជាលិខិតុបករណ៍អន្តរជាតិដំបូងដែលផ្តោតលើតែ អ.ក.ស.ម។ ទោះបីជាលិខិតុបករណ៍នេះមិនចងកាតព្វកិច្ចផ្លូវច្បាប់ ក៏សេចក្តីប្រកាសនេះត្រូវបានមហាសន្និបាតអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៨ អនុម័តសម្រេចជាឯកច្ឆន្ទក្នុងឱកាសខួបលើកទី៥០ ឆ្នាំនៃ ស.ប.ស.ស ។ ការអនុម័តជាឯកច្ឆន្ទនេះបានបង្ហាញពីជំហានដ៏សំខាន់ឆ្ពោះទៅរកការទទួលស្គាល់ជាអន្តរជាតិចំពោះការងាររបស់ អ.ក.ស.ម និងគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការការពារ អ.ក.ស.ម។ សេចក្តីប្រកាសនេះមិនបានបង្កើតសិទ្ធិថ្មីដោយឡែកឡើយ ប៉ុន្តែបានបញ្ជាក់សាជាថ្មីពីសិទ្ធិក្នុងការលើកកម្ពស់ និងទាមទារឲ្យ

---

[13]ពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី ថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៩៩ អាចរកបានតាមរយៈ ៖ http://www2.ohchr.org/english/law/pdf/cedaw-one.pdf

[14]សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ៖ "សេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងស្ថាប័នសង្គមក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល" (ថ្ងៃទី៨ ខែមិនា ឆ្នាំ១៩៩៩) ឯកសារអង្គការសហប្រជាជាតិ A/RES/53/144 http://bit.ly/19w8LEm

មានការការពារ និងទទួលស្គាល់សិទ្ធិមនុស្សនិងសេរីភាពមូលដ្ឋាន[15]សិទ្ធិសេរីភាពខាងការបញ្ចេញមតិ[16] និងការជួបប្រជុំដោយសន្តិវិធី[17]និងសិទ្ធិបង្កើតនិងចូលរួមក្នុងអង្គការមិនមែនរដ្ឋាភិបាលសមាគមឬក្រុម[18]។ លើសពីនេះទៅទៀត សេចក្តីប្រកាសនេះបានបញ្ជាក់ឡើងវិញពីភារកិច្ចមួយចំនួនរបស់ អ.ក.ស.ម និងរដ្ឋ។ សេចក្តីសម្រេចជាបន្តបន្ទាប់ដោយមហាសន្និបាតអង្គការសហប្រជាជាតិ[19] និងក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ[20]បានបញ្ជាក់ឡើងវិញពីសារៈសំខាន់នៃសិទ្ធិដែលមានចែងក្នុង ស.ប.ស.ស និងជំរុញឲ្យរដ្ឋចាត់វិធានការការពារជាក់លាក់ដើម្បីធានាសុវត្ថិភាពរបស់ អ.ក.ស.ម។

សេចក្តីប្រកាសនេះបានកំណត់ អ.ក.ស.ម ថា រូបវន្តបុគ្គល ឬក្រុម និងសមាគមដែលធ្វើការលុបបំបាត់ការរំលោភសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានរបស់មនុស្សគ្រប់រូប និងបុគ្គលណាមួយ។ សិទ្ធិទាំងនេះអាចជាសិទ្ធិពលរដ្ឋ នយោបាយ សេដ្ឋកិច្ច សង្គម និង/ឬវប្បធម៌ និងអាចគ្របដណ្តប់លើបញ្ហានានាដែលមានចាប់ពីការរើសអើងជាតិសាសន៍រហូតដល់ការបណ្តេញចេញដោយបង្ខំ។ អ.ក.ស.ម ជាទូទៅមានដូចជា អ្នកដែលមានវិជ្ជា

---

[15]ដូចខាងលើ មាត្រា (១)

[16]ដូចខាងលើ មាត្រា (៦)

[17]ដូចខាងលើ មាត្រា ៥ (a)

[18]ដូចខាងលើ មាត្រា ៥ (b) និង (c)

[19]សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ៖ "ការជំរុញសេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងស្ថាប័នសង្គមក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល" (ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១១) ឯកសារអង្គការសហប្រជាជាតិ A/RES/66/164 http://bit.ly/1qiUIfU

[20]ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ៖ "ការការពារអ្នកការពារសិទ្ធិមនុស្ស" (ថ្ងៃទី១៩ ខែមិនា ឆ្នាំ ២០១០) ឯកសារអង្គការសហប្រជាជាតិ A/HRC/13/L.24, http://bit.ly/1tXQIlo សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ៖ "ការលើកកម្ពស់សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានតាមរយៈការយល់ដឹងល្អប្រសើរពីតម្លៃប្រពៃណីរបស់មនុស្សជាតិ" (ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១) ឯកសារអង្គការសហប្រជាជាតិ A/HRC/RES/16/3 http://goo.gl/kfaf8Z ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ៖ "ការការពារអ្នកការពារសិទ្ធិមនុស្ស" (ថ្ងៃទី១៥ ខែមិនា ឆ្នាំ២០១៣) ឯកសារអង្គការសហប្រជាជាតិ A/HRC/22/L.13 http://bit.ly/YXSF7Y

ជីវៈផ្នែកសិទ្ធិមនុស្ស សារព័ត៌មាន មេធាវីឬតំណាងសហគមន៍ ប៉ុន្តែមនុស្សជាច្រើនទៀតក៏មានលក្ខណៈសម្បត្តិជា អ.ក.ស.ម ដែរ[21]។ ដើម្បីអាចចាត់ថ្នាក់ជា អ.ក.ស.ម ទាល់តែបុគ្គលទាំងនោះត្រូវតែអហិង្សា និងទទួលស្គាល់ភាពជាសកលនៃសិទ្ធិមនុស្ស។ អ.ក.ស.ម អាចបំពេញការងារជាច្រើនដូចជា ចងក្រងឯកសារការរំលោភសិទ្ធិមនុស្ស ផ្តល់ការអប់រំឬការបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្ស ធ្វើការតវ៉ាទាមទារឲ្យមានការយកចិត្តទុកដាក់លើបញ្ហាបរិស្ថាន ការលើកកម្ពស់ការយល់ដឹង។ល។ ពាក់ព័ន្ធនឹង អ.ក.ស.ម.ស សេចក្តីប្រកាសនេះបានអនុវត្តដោយស្មើភាពរវាងបុរសនិងស្ត្រី។

ក្រៅពីបង្ហាញពីសិទ្ធិរបស់ អ.ក.ស.ម សេចក្តីប្រកាសនេះបានគូសបញ្ជាក់ពីភារកិច្ចរបស់រដ្ឋាភិបាលក្នុងការធានាការការពារដល់ អ.ក.ស.ម។ យោងតាមមាត្រា ១២(២) អាជ្ញាធរពាក់ព័ន្ធត្រូវការពារ អ.ក.ស.ម ពីការចាប់ខ្លួន អំពើហិង្សា ការគំរាមកំហែង ការសងសឹង និងការរើសអើងដែលកើតចេញពីសកម្មភាពរបស់ អ.ក.ស.ម ព្រមទាំងបានបញ្ជាក់ថា អ.ក.ស.ម គួរទទួលបានការការពារក្រោមច្បាប់ជាតិ។ សេចក្តីប្រកាសនេះបានអះអាងថា អ.ក.ស.ម មានសិទ្ធិប្រឆាំងនឹងសកម្មភាពនានាដូចជា សកម្មភាពកើតចេញពីការមិនអើពើ សកម្មភាពរបស់រដ្ឋដែលធ្វើឲ្យមានការរំលោភសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។

មានយន្តការបន្ថែមជួយដល់ការការពារ អ.ក.ស.ម នៅកម្រិតអន្តរជាតិ។ កាលពីឆ្នាំ២០០០ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស បានបង្កើតឲ្យមានអ្នករាយការណ៍ពិសេសស្តីពីស្ថានភាព អ.ក.ស.ម ("អ្នករាយការណ៍ពិសេស") សម្រាប់អាណត្តិរបស់ខ្លួនក្នុងការជួយសម្រួលដល់ការអនុវត្តសេចក្តីប្រកាសស្តីពី អ.ក.ស.ម។ អ្នករាយការណ៍ពិសេសអាចទទួលបានព័ត៌មាន និងបណ្តឹងបុគ្គលស្តីពីការរំលោភសិទ្ធិ

[21]ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) "សលាកប័ត្រព័ត៌មានលេខ២៩ ៖ អ្នកការពារសិទ្ធិមនុស្ស ៖ ការការពារសិទ្ធិក្នុងការការពារសិទ្ធិមនុស្ស" (ខែមេសា ឆ្នាំ២០០៤) http://goo.gl/EnVkvy

របស់ អ.ក.ស.ម និងអាចទាក់ទងជាមួយរដ្ឋសមាជិកដែលពាក់ព័ន្ធនឹងករណីទាំងនេះ។ អ្នករាយការណ៍ពិសេសត្រូវធ្វើទស្សនកិច្ចផ្លូវរដ្ឋដើម្បីស៊ើបអង្កេតពីស្ថានភាពរបស់ អ.ក.ស .ម ក្នុងប្រទេសណាមួយជាក់លាក់ និងបង្ហាញរបាយការណ៍ប្រចាំឆ្នាំដល់ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ[22]។

នៅឆ្នាំ១៩៩៥ សន្និសីទពិភពលោកលើកទី៤ របស់អង្គការសហប្រជាជាតិស្តីពីស្ត្រីបានបង្កើត "វេទិកាសកម្មភាពទីក្រុងប៉េកាំង" ហើយមាត្រា ២២៨ បានចែងថា *"ស្ត្រីដែលចូលរួមក្នុងការការពារសិទ្ធិមនុស្សត្រូវទទួលបានការការពារ"*។[23] នៅខែធ្នូ ឆ្នាំ២០១០ អ្នករាយការណ៍ពិសេសស្តីពីស្ថានភាព អ.ក.ស.ម អ្នកស្រី ម៉ាហ្គារេត សេកាហ្គយ៉ា បានផ្តោតលើហានិភ័យ និងបញ្ហាប្រឈមរបស់ អ.ក.ស.ម.ស ដោយដាក់ក្នុងរបាយការណ៍ប្រចាំឆ្នាំលើកទីបីរបស់គាត់[24]។ នេះជាជំហានដ៏សំខាន់មួយក្នុងការទទួលស្គាល់ទស្សនវិស័យយេនឌ័រនៃការងាររបស់ អ.ក.ស.ម ។

ការវិវឌ្ឍដ៏សំខាន់មួយក្នុងការការពារ អ.ក.ស.ម.ស គឺសេចក្តីសម្រេចលេខ ៦៨/១៨១ ដែលអនុម័តកាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣ ដោយមហាសន្និបាតអង្គការសហប្រជាជាតិ[25]ស្តីពី " *ការលើកកម្ពស់សេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់*

---

[22]អ្នកស្រី ម៉ាហ្គារេត សេកាហ្គយ៉ា កាន់តំណែងក្នុងអំឡុងឆ្នាំ២០០៨- ២០១៤ និងបន្តវេនដោយ មីសែល ហ្វ័ស្តដែលត្រូវបានចាត់តាំងនៅខែមិថុនា ឆ្នាំ២០១៤។ សូមមើល ៖ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស "អ្នករាយការណ៍ពិសេសស្តីពីស្ថានភាព អ.ក.ស.ម" http://bit.ly/1q1Hfc6

[23] សន្និសីទពិភពលោករបស់អង្គការសហប្រជាជាតិស្តីពីស្ត្រីឆ្នាំ១៩៩៥ "វេទិកាសកម្មភាពទីក្រុងប៉េកាំង" មាត្រា ២២៨។ អាចរកបានតាមរយៈ <http://www.un.org/womenwatch/daw/beijing/platform/human.htm>

[24]របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស ៖ ម៉ាហ្គារេត សេកាហ្គយ៉ា (A/HRC/16/44 ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០)។ អាចរកបានតាមរយៈ ៖ http://www2.ohchr.org/english/bodies/hrcouncil/docs/16session/A-HRC-16-44.pdf

[25]ការជំរុញសេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងស្ថាប័នសង្គមក្នុងការលើកកម្ពស់និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល ៖ ការការពារស្ត្រីអ្នកការពារសិទ្ធិមនុស្ស"(ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤) A/RES/68/181 អាចរកបានតាមរយៈ ៖ http://www.un.org/en/ga/search/view_doc.asp?symbol=A/RES/68/181

*បុគ្គល ក្រុម និងស្ថាប័នសង្គមក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកល ៖ ការការពារស្ត្រី អ.ក.ស.ម.ស។*

សេចក្តីសម្រេចនេះបានអំពាវនាវឲ្យរដ្ឋចាត់វិធានការជាក់ស្តែង ម៉ឺងម៉ាត់ និងសមស្របដើម្បីការពារ អ.ក.ស.ម.ស ដោយបញ្ជាក់ថាការគោរពសកម្មភាពរបស់ អ.ក.ស.ម.ស មានសារៈសំខាន់ក្នុងការទទួលបានសិទ្ធិមនុស្សជារួម និងបង្ហាញពីក្តីបារម្ភចំពោះការរើសអើងនិងអំពើហិង្សាជាប្រព័ន្ធដែលមានរចនាសម្ព័ន្ធដែល អ.ក.ស.ម.ស ជួបប្រទះ។ បន្ទាប់មក សេចក្តីប្រកាសបានជំរុញឲ្យរដ្ឋផ្តល់ភាពស្របច្បាប់ដល់តួនាទីរបស់ អ.ក.ស.ម ស្ត្រីក្នុងការលើកកម្ពស់និងការពារសិទ្ធិមនុស្ស ដោយអំពាវនាវឲ្យរដ្ឋធានាថាអ្នកការពារសិទ្ធិមនុស្សស្ត្រី មានសិទ្ធិស្របច្បាប់ក្នុងការងារ ឬវិជ្ជាជីវៈរបស់ខ្លួនប្រកបដោយសេចក្តីថ្លៃថ្នូរ។

## ១.២ ក្របខ័ណ្ឌច្បាប់ថ្នាក់តំបន់

នៅថ្នាក់តំបន់ ស្ថាប័នអន្តររដ្ឋាភិបាលថ្នាក់តំបន់មួយចំនួនបានបង្កើតយន្តការពិសេសដើម្បីបំពេញបន្ថែម ក្របខ័ណ្ឌការពារជាអន្តរជាតិ ដើម្បីបង្ហាញពីការទទួលស្គាល់កាន់តែទូលំទូលាយពីសារៈសំខាន់នៃការងាររបស់ អ.ក.ស.ម ទាំងស្ត្រី និងបុរស។

ជាងនេះទៅទៀត អង្គការអន្តររដ្ឋាភិបាលនៅថ្នាក់តំបន់ទាំងអស់បានដាក់ចេញនូវការការពារជាក់លាក់សំខាន់ៗពាក់ព័ន្ធនឹង អ.ក.ស.ម។ ទាំងអន្តរគណៈកម្មការអាមេរិកទទួលបន្ទុកសិទ្ធិមនុស្ស និងគណៈកម្មការអាហ្វ្រិកស្តីពីមនុស្ស និងសិទ្ធិមនុស្ស បានបង្កើតអ្នករាយការណ៍ពិសេសស្តីពី អ.ក.ស.ម ។ តួអង្គទាំងនេះមានតួនាទីរៀបចំការសិក្សា ធ្វើទស្សនកិច្ចផ្លូវរដ្ឋ ស្វែងរក និងទទួលព័ត៌មានស្តីពីស្ថានភាព អ.ក.ស.ម ក្នុងទ្វីបរបស់ពួកគេ។ លើសពីនេះ តុលាការអន្តរអាមេរិកទទួលបន្ទុកសិទ្ធិមនុស្សអាចពិចារណាពីករណីដែលរងការចោទប្រកាន់ពីការរំលោភសិទ្ធិមនុស្សរួមទាំងជនដៃដល់ដែលប្រឆាំងនឹង អ.ក.ស.ម ផងដែរ។

នៅអឺរ៉ុប សហភាពអឺរ៉ុប បានចេញផ្សាយគោលការណ៍ណែនាំរបស់សហភាពអឺរ៉ុបស្តីពី អ.ក.ស.ម ដែលកំណត់ពីគោលនយោបាយរបស់សហភាពក្នុងការការពារបុគ្គល

នៅក្រៅតំបន់អឺរ៉ុប។ សម្រាប់រដ្ឋជាសមាជិកនៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស បុគ្គលដែលរងគ្រោះពីការរំលោភសិទ្ធិមនុស្សនឹងទទួលបានដំណោះស្រាយផ្លូវច្បាប់តាមរយៈតុលាការអឺរ៉ុបទទួលបន្ទុកសិទ្ធិមនុស្ស។ ស្រដៀងគ្នានេះដែរ គោលការណ៍ណែនាំរបស់អង្គការដើម្បីសន្តិសុខ និងកិច្ចសហប្រតិបត្តិការអឺរ៉ុប("OSCE") ស្តីពីការការពារ អ.ក.ស.ម[26]បានអំពាវនាវឲ្យរដ្ឋជាសមាជិករបស់ខ្លួនបង្កើតយន្តការការពារ អ.ក.ស.ម ទាំងក្នុងបូរណភាពដែនដីរបស់ខ្លួន និងក្រៅដែនដីក្នុងប្រទេសទី៣ តាមរយៈទំនាក់ទំនងការទូត។

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ("អាស៊ាន") ដើរតាមអង្គការអន្តររដ្ឋាភិបាលថ្នាក់តំបន់ផ្សេងទៀតពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្ស ហើយមិនបានផ្តល់ការការពារគ្រប់គ្រាន់ដល់ អ.ក.ស.ម ក្នុងតំបន់របស់ខ្លួនឡើយ។ តាមពិតទៅ អាស៊ានមានភាពយឺតយ៉ាវក្នុងការបង្កើតឲ្យមានស្ថាប័នសិទ្ធិមនុស្សនៅក្នុងរចនាសម្ព័ន្ធរបស់ខ្លួន៖ គណៈកម្មការអន្តររដ្ឋាភិបាលស្តីពីសិទ្ធិមនុស្ស ("AICHR") បានចាប់ដំណើរការនៅឆ្នាំ២០០៩ ហើយអណត្តិការទាមទាររបស់ខ្លួនមិនមានបទប្បញ្ញត្តិជាក់លាក់ណាមួយចែងពីសិទ្ធិអំណាចក្នុងការទទួលពាក្យបណ្តឹង និងស៊ើបអង្កេតទៅលើករណីបណ្តឹងពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សនោះទេ។ ក្រៅពីនេះ សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ានដែលត្រូវបានអនុម័តនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១២ នៅរាជធានីភ្នំពេញ មិនមានបទប្បញ្ញត្តិពាក់ព័ន្ធនឹង អ.ក.ស.ម ឡើយ។ ប៉ុន្តែសេចក្តីប្រកាសនេះបានប្រកាសពីសិទ្ធិទទួលបានសមភាពយេនឌ័រនិងសិទ្ធិសេរីភាពខាងការបញ្ចេញមតិយោបល់ គំនិត ទស្សនៈ និងសេរីភាពខាងការជួបប្រជុំ ព្រមទាំង "*សិទ្ធិចូលរួមក្នុងរដ្ឋាភិបាលក្នុងប្រទេសរបស់ខ្លួន។* យ៉ាងណាក៏ដោយ សេចក្តីប្រកាសនេះបានទទួលរងការរិះគន់យ៉ាងខ្លាំង[27]ដោយសារតែបទប្បញ្ញត្តិដែលអនុញ្ញាត

---

[26]គោលការណ៍ណែនាំស្តីពីការការពារអ្នកការពារសិទ្ធិមនុស្ស អាចរកបានតាមរយៈ ៖ http://www.osce.org/odihr/119633?download=true

[27]គំនិតផ្តួចផ្តើមនីតិរដ្ឋរបស់គណៈមេធាវីសហរដ្ឋអាមេរិក ៖ "សេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន ៖ ការវិភាគផ្លូវច្បាប់"អាចរកបានតាម<http://www.americanbar.org/content/dam/aba/directories /roli/asean/asean -human-rights-declaration-legal-analysis-2014.authcheckdam.pdf>

ឲ្យមានការរឹតត្បិតលើសិទ្ធិទាំងអស់ "*ដោយគ្រាន់តែបំពេញលក្ខខណ្ឌ សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈ សុវត្ថិភាពសាធារណៈ សីលធម៌សាធារណៈ និងសុខុមាលភាពរួមរបស់ប្រជាជនក្នុងសង្គមប្រជាធិបតេយ្យ*" (មាត្រា ៨) ដែលអនុញ្ញាតឲ្យរដ្ឋ "*ពិចារណាពីបរិបទជាតិ និងតំបន់*" (មាត្រា ៦ និង ៧)។ សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ានយកគំរូតាម និងពង្រីកលើ "សេចក្តីប្រកាសឆ្នាំ១៩៨៨ ស្តីពីការជំរុញស្ត្រីក្នុងតំបន់អាស៊ាន" និង "សេចក្តីប្រកាសឆ្នាំ២០០៤ ស្តីពីការលុបបំបាត់អំពើហិង្សាប្រឆាំងនឹងស្ត្រីក្នុងតំបន់អាស៊ាន។

## ១.៣ ក្របខ័ណ្ឌច្បាប់ជាតិ

ច្បាប់ក្នុងស្រុករបស់ប្រទេសកម្ពុជា មិនបានផ្តល់នូវការការពារជាក់លាក់ដល់ អ.ក.ស.ម ឡើយ បើទោះបីជារដ្ឋធម្មនុញ្ញ[28]ការពារសេរីភាពមូលដ្ឋាន ហើយនៅក្នុងមាត្រា ៣១ គឺទទួលស្គាល់សិទ្ធិមនុស្ស ដូចមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិនានា។ មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញក៏បានចែងថា "*ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ*" ។ មាត្រា ៣៥ បានផ្តល់ដល់ប្រជាពលរដ្ឋនូវ "*សិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ*" ហើយមាត្រា ៣៧ ផ្តល់នូវ "*សិទ្ធិធ្វើកូដកម្ម និង ធ្វើបាតុកម្មដោយសន្តិវិធី*"។ កាតព្វកិច្ចរបស់កម្ពុជាក្រោមច្បាប់អន្តរជាតិគឺមិនត្រឹមតែមានចែងក្នុងមាត្រា ៣១ នៅក្នុងរដ្ឋធម្មនុញ្ញប៉ុណ្ណោះទេ ប៉ុន្តែការអនុវត្តជាក់ស្តែងត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាកាលពីឆ្នាំ២០០៧[29] ដែលបានបញ្ជាក់ថា សន្ធិសញ្ញាអន្តរជាតិអាចយកមកអនុវត្តបានចំពោះមុខតុលាការ ដូច្នេះ

---

[28]រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤ អាចរកបានតាមរយៈ <http://cambodia.ohchr.org/klc_pages/KLC_files/section_001/section_01_01_ENG.pdf >

[29]ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញកម្ពុជាសេចក្តីសម្រេចលេខ 092/003/2007 (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧)

ពុំមានច្បាប់ណាត្រូវបានប្រើប្រាស់ដោយផ្ទុយពីរដ្ឋធម្មនុញ្ញ ឬសន្ធិសញ្ញាទាំងឡាយពាក់ព័ន្ធនឹងសិទ្ធិមនុស្សដែលកម្ពុជាជារដ្ឋភាគីនោះឡើយ។ ក្រៅពីបញ្ញត្តិទាំងនេះ ពុំមានយន្តការសិទ្ធិមនុស្សណាមួយដែលអាចការពារ អ.ក.ស.ម ឲ្យរួចផុតពីការរំលោភបំពាន ឬជានាសងជំងឺចិត្ត និងការខូចខាតឡើយ។

ក្នុងអំឡុងពេលនៃការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ មានរដ្ឋចំនួន៩[30]បានផ្តល់អនុសាសន៍ដល់រាជរដ្ឋាភិបាលកម្ពុជាត្រូវធ្វើឲ្យប្រសើរឡើងចំពោះកិច្ចការពារ អ.ក.ស.ម ឧទាហរណ៍ ការចូលរួមក្នុងកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិជាមួយ អ.ក.ស.ម ឆ្លើយតបទៅនឹងបទដ្ឋានសេរីភាពខាងការបញ្ចេញមតិអន្តរជាតិ ហើយបញ្ឈប់សកម្មភាពសម្លុតបំភ័យ ឬយាយី អ.ក.ស.ម។ រដ្ឋាភិបាលបានទទួលយកអនុសាសន៍ភាគច្រើនរួមទាំងអនុសាសន៍៧ ដែលពាក់ព័ន្ធដោយផ្ទាល់នឹង អ.ក.ស.ម ដូចជា អនុសាសន៍របស់សាធារណៈរដ្ឋឆេក ដែលបានស្នើឲ្យមានការកែប្រែក្រមព្រហ្មទណ្ឌ និងច្បាប់ផ្សេងទៀតដើម្បីឲ្យស្របតាមស្តង់ដារអន្តរជាតិនៃសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងការពាររាល់ការយាយីដល់ អ.ក.ស.ម អ្នកសារព័ត៌មាន និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងអនុសាសន៍របស់ប្រទេសអូទ្រីសធ្វើឲ្យមានការគោរព និងការពារសិទ្ធិរបស់ អ.ក.ស.ម និងអ្នកសារព័ត៌មានដើម្បីបំពេញការងារដោយគ្មានការរារាំង ការសម្លុតបំភ័យ ឬយាយី។ ប៉ុន្តែទោះជាយ៉ាងណាក្តី កម្ពុជាមិនគាំទ្រអនុសាសន៍របស់ប្រទេសទុយនេស៊ី ដែលសុំឲ្យមានការធានាបរិយាកាសប្រសើរជាងមុនសម្រាប់សកម្មភាពរបស់ អ.ក.ស.ម ហើយក៏មិនទទួលយកអនុសាសន៍របស់ប្រទេសប៉ូឡូញសុំឲ្យមានការការពារ អ.ក.ស.ម ពីការយាយី និងការចាប់ខ្លួនតាមអំពើចិត្ត ព្រមទាំងលុបចោលរាល់ការរឹតត្បិត

[30]អៀរឡង់ សាធារណរដ្ឋឆែក អូទ្រីស ឈីលី នូវែលហ្សេឡង់ បែលហ្សិច បារាំង អាល្លឺម៉ង់ ព័រទុយហ្កាល់ និងទុយនេស៊ី បានផ្តល់អនុសាសន៍ពីប្រធានបទនេះ។ សូមមើល ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "របាយការណ៍របស់ក្រុមការងារស្តីពីការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ស្តីពីកម្ពុជា" (ថ្ងៃទី២៧ ខែមិនា ឆ្នាំ២០១៤) ឯកសារអង្គការសហប្រជាជាតិ A/HRC/26/16 http://goo.gl/XzZk9M

ចំពោះការតវ៉ាដោយសន្តិវិធី។ ទោះជាយ៉ាងណាក្តី រាជរដ្ឋាភិបាលកម្ពុជាមិនបានបង្កើតគោលការណ៍ណាមួយ ឬចាត់វិធានការណាមួយដាក់លាក់ដើម្បីការពារ អ.ក.ស.ម ឡើយ។

កម្ពុជាមានគណៈកម្មាធិការបីដែលធ្វើការពាក់ព័ន្ធនឹងសិទ្ធិមនុស្សគឺ គណៈកម្មាការសិទ្ធិមនុស្សរបស់ព្រឹទ្ធសភា គណៈកម្មាការសិទ្ធិមនុស្សរបស់រដ្ឋសភា និងគណៈកម្មាធិការសិទ្ធិមនុស្សរបស់រដ្ឋាភិបាល។ ទោះជាយ៉ាងណាក៏ដោយ ក្នុងចំណោមគណៈកម្មាធិការទាំងបី គ្មានគណៈកម្មាធិការណាមួយដែលឯករាជ្យ ឬស្វយ័តនោះទេ គណៈកម្មាធិការទាំងនោះត្រូវទទួលរងឥទ្ធិពលនយោបាយ និងបន្ទប់បង្អាក់សមត្ថភាពរបស់ពួកគេក្នុងការអនុវត្តតួនាទីឲ្យមានប្រសិទ្ធភាព [31]។ តាមរយៈសន្និសីទស្តីពីការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិក្នុងឆ្នាំ២០០៦ រដ្ឋាភិបាលបានប្តេជ្ញាចិត្តបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ ដោយយោងទៅលើគោលការណ៍ទីក្រុងប៉ារីស ពហុនិយម និងឯករាជ្យ ព្រមទាំងបង្កើតក្រុមការងាររួមរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល[32]។ ក្នុងអំឡុងពេលនៃការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ស្តីពីកម្ពុជា មានប្រទេសចំនួន១០[33]បានផ្តល់អនុសាសន៍ឲ្យកម្ពុជាត្រូវបង្កើនល្បឿនបង្កើតស្ថាប័ននេះ។ បើទោះជាយ៉ាងនេះក្តី ច្បាប់នេះស្ថិតនៅក្នុងដំណាក់កាលព្រាងនៅឡើយ។ ម្យ៉ាងទៀត រដ្ឋាភិបាលនៅមិនទាន់បានផ្តល់សច្ចាប័នលើពិធីសារបន្ថែមទីមួយលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ពាក់ព័ន្ធនឹងការទទួលយកនីតិវិធីបណ្តឹងបុគ្គលដែលទទួលស្គាល់សិទ្ធិអំណាចរបស់គណៈកម្មាធិការ

---

[31]ម.ស.ម.ក សលាកប័ត្រព័ត៌មាន ៖ "កម្រងឯកសារស្តីពីស្ថាប័ន ៖ ស្ថាប័នសិទ្ធិមនុស្សជាតិនៅកម្ពុជា" (ខែមិនា ឆ្នាំ២០១២) http://goo.gl/VNq21u

[32]វេទិកាអាស៊ីប៉ាស៊ីហ្វិច "សន្និសីទស្តីពីការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិនៅកម្ពុជា" (ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ ២០០៦) http://bit.do/YFMn

[33]ឈីលី មីយ៉ាន់ម៉ា ស៍រប៊ី អេហ្សីប ឥណ្ឌា ថៃ ម៉ាឡេស៊ី ម៉ូរ៉ូកូ ប៉ាគីស្ថាន និងអូស្ត្រាលី ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "ការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ស្តីពីកម្ពុជា" (ក ៣២)។

សិទ្ធិមនុស្សអង្គការសហប្រជាជាតិដើម្បីទាក់ទងជាមួយជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សនៅឡើយដែរ។

**តារាង ១.១ ៖ សិទ្ធិពាក់ព័ន្ធបំផុតដែលត្រូវបានការពារដោយច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ**

| | រដ្ឋធម្មនុញ្ញ | ក.អ.ស.ព.ន | ស៊ី-ដ | អ.ក.ស.ម អាស៊ាន | ស.ប.ស.ស |
|---|---|---|---|---|---|
| សេរីភាពក្នុងការជួបប្រជុំ | ✓ | ✓ | | ✓ | ✓ |
| សេរីភាពខាងការបញ្ចេញមតិ | ✓ | ✓ | | ✓ | ✓ |
| សេរីភាពខាងសមាគម | ✓ | ✓ | | ✓ | ✓ |
| សមភាពយេនឌ័រ | ✓ | ✓ | ✓ | ✓ | ✓ |
| ការចូលរួមក្នុងកិច្ចការសាធារណៈ | ✓ | ✓ | ✓ | ✓ | ✓ |
| សិទ្ធិទទួលបានការជុំនុំជម្រះដោយយុត្តិធម៌ | ✓ | ✓ | | ✓ | ✓ |

## ២. ស្ថានភាពរបស់ស្ត្រីនៅកម្ពុជា

នៅកម្ពុជា មានចំនួនស្ត្រីប្រមាណ ៥១,២៣% នៃប្រជាជនសរុប។[34] ប៉ុន្តែតួលេខនេះមិនបានឆ្លុះបញ្ចាំងពីការបែងចែកយេនឌ័រក្នុងការចូលរួមកិច្ចការសាធារណៈក្នុងប្រទេសឡើយ។ ដូចមានបង្ហាញនៅក្នុងគោលនយោបាយសង្ខេបពីមុនរបស់ ម.ស.ម.ក[35]ចំនួនសមាសភាពតំណាងជាស្ត្រីក្នុងឆាកនយោបាយមានចំនួនតិចតួច។ ជាក់ស្តែង រដ្ឋសភាជាតិមានតំណាងរាស្ត្រស្ត្រីត្រឹមតែ ២២% ប៉ុណ្ណោះ។ ខណៈដែលនៅថ្នាក់ឃុំ/សង្កាត់ ភាគរយនេះកាន់តែទាបប្រមាណតែ ១៧,៧៩%។ អត្រានេះមិនទាន់បំពេញតាមគោលដៅក្នុងការចូលរួមប្រមាណ ៣០% នៅឆ្នាំ២០១៥ នៅថ្នាក់ជាតិ( ២៥% សម្រាប់សង្កាត់/ឃុំ ) ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងគោលដៅអភិវឌ្ឍសហសវត្សរ៍កម្ពុជានៅឡើយទេ។ វិសមភាពក្នុងការចូលរួមនេះកើតចេញពីការយល់ឃើញខុសដែលចាក់ឫសក្នុងសង្គមកម្ពុជាតាមរយៈសុភាសិតខ្មែរដែលយល់ថា "បុរសគឺជាមាស ឬឯស្ត្រីជាកំណាត់។ ស្ត្រីត្រូវបានចាត់ទុកថាមានឋានៈតូចទាប មិនសូវឆ្លាត និងផលិតភាពតិចជាងបុរស ហើយស្ត្រីត្រូវធ្វើការងារផ្ទះសម្បែង និងមើលថែទាំគ្រួសារ។ ភារកិច្ចក្នុងគ្រួសារគឺជាការកំណត់របស់សង្គម ដែលរារាំងស្ត្រីក្នុងការបន្តការសិក្សានិងអាជីពរបស់ខ្លួន ។

ផ្នត់គំនិតយេនឌ័រចាស់គំរិលដ៏គ្រោះថ្នាក់នេះ បានចាក់ឫសយ៉ាងជ្រៅក្នុងប្រពៃណីវប្បធម៌កម្ពុជា ដូចមានបង្ហាញនៅក្នុងច្បាប់ស្រី ដែលជាស្នាដៃអក្សរសាស្ត្រខ្មែរត្រូវបានចងក្រងតាំងពីមុនសតវត្សរ៍ទី១៤ និងបន្តមានឥទ្ធិពលរហូតមកដល់សព្វថ្ងៃនេះ។

---

[34]ធនាគារពិភពលោកឆ្នាំ ២០១៤។

[35]គោលនយោបាយសង្ខេប ៖ សមាសភាពស្ត្រីក្នុងឆាកនយោបាយនៅកម្ពុជា អាចរកបានតាមរយៈ ៖ http://www.cchrcambodia.org/admin/media/analysis/analysis/english/2013_07_26_CCHR_Policy_Brief%20_%20Women_s_Political_Representation_in_Cambodia_ENG_Final.pdf

ច្បាប់ស្រីពន្យល់ថាស្ត្រី *«គួរតែបម្រើប្តី និងស្តាប់តាមបង្គាប់របស់ប្តី ត្រូវនិយាយស្តីរាបសារ មិននិយាយរឿងរ៉ាវក្នុងគ្រួសារប្រាប់អ្នកដទៃ ទទួលយកពាក្យអសុរោះពីប្តីដោយមិនត្អូញត្អែរ និងមិនត្រូវចាត់ទុកថាខ្លួនមានឋានៈស្មើនឹងប្តីឡើយ។ ស្របគ្នាជាមួយនឹងក្រមនេះ តាមប្រពៃណីទំនៀមទម្លាប់ ស្ត្រីត្រូវមើលថែគ្រួសារ និងចិញ្ចឹមកូន»*។[36]

នៅក្នុងកម្រិតនេះ យោងទៅលើរបាយការណ៍សកលស្តីពីគម្លាតយេនឌ័រឆ្នាំ ២០១៤ ("របាយការណ៍")[37] កម្ពុជាជាប់ចំណាត់ថ្នាក់លេខ ១០៨ ក្នុងចំនោមប្រទេស ១៤២ ស្តីពីសមភាពយេនឌ័រដោយទទួលបានពិន្ទុ ០,៦៥។ របាយការណ៍នេះ គឺជារបាយការណ៍សន្ទស្សន៍ដែលត្រូវបានបោះពុម្ពផ្សាយតាំងពីឆ្នាំ២០០៦ ដោយវេទិកាសេដ្ឋកិច្ចពិភពលោក ហើយធ្វើចំណាត់ថ្នាក់ប្រទេសទៅតាមគម្លាតយេនឌ័រ។ របាយការណ៍នេះពិនិត្យមើលទៅលើផ្នែកសំខាន់ ៤ នៃវិសមភាព ៖ "ការចូលរួមក្នុងវិស័យសេដ្ឋកិច្ច និងឱកាស" "ការទទួលការអប់រំ" "ការពង្រឹងអំណាចនយោបាយ" និង "សុខភាព និងការរស់រានមានជីវិត។ របាយការណ៍នេះបានកំណត់ច្បាស់ពីគម្លាតយ៉ាងខ្លាំងរវាងឋានៈនិងការយកចិត្តទុកដាក់មកលើស្ត្រី និងបុរស។ ជាក់ស្តែង ខណៈដែលស្ត្រីចំនួន ៨២% មានការងារធ្វើ (ធៀបនឹងបុរស ៨៨%) ប្រាក់ចំណូលមធ្យមរបស់ស្ត្រីគឺ ១.០០០ ដុល្លាក្នុងមួយឆ្នាំតិចជាងបុរស។ មានន័យថាស្ត្រីដែលមានការងារធ្វើទទួលបានប្រាក់ចំណូលទាប ដែលជាក់ស្តែងមានស្ត្រីតែ ៣៥% ប៉ុណ្ណោះដែលបំពេញការងារវិជ្ជាជីវៈ និងការងារបច្ចេកទេស ធៀបនឹងបុរសមានដល់ ៦៥%។ ចំពោះការអប់រំវិញ អត្រាអក្ខរភាព ៦៦% សម្រាប់ស្ត្រី និង ៨៣% សម្រាប់បុរស ដែលគូសបញ្ជាក់ពីភាពខុសគ្នាយ៉ាងខ្លាំង ខណៈដែលស្ត្រីកម្ពុជាប្រមាណតែ ១២% ប៉ុណ្ណោះដែលទទួលបានការអប់រំនៅសាកលវិទ្យាល័យ។

---

[36] [36]SinaBrod ៖ យេនឌ័រនៅកម្ពុជា-ភូមិសាស្ត្រកម្ពុជា ខែមករា ឆ្នាំ២០១៤ អាចរកបានតាមរយៈ ៖ <https://www.academia.edu/7702162/Gender_in_Cambodia._A_brief_overview>

[37] របាយការណ៍គម្លាតយេនឌ័រ ឆ្នាំ២០១៤ កម្ពុជា អាចរកបានតាមរយៈ ៖ http://reports.weforum.org/global-gender-gap-report-2014/economies/#economy=KHM

អំពើហិង្សាក្នុងគ្រួសារនៅតែជាបញ្ហាចម្បងក្នុងប្រទេសកម្ពុជា។ របាយការណ៍ស្រាវជ្រាវឆ្នាំ២០១៥ របស់អង្គការសុខភាពពិភពលោក[38]បានរកឃើញថា អ្នកដែលបានឆ្លើយក្នុងការស្ទង់មតិប្រមាណ ២១% បានឆ្លងកាត់អំពើហិង្សាផ្លូវភេទ ឬអំពើហិង្សាលើរាងកាយពីដៃគូរបស់ខ្លួន។ អ្វីដែលគួឲ្យព្រួយបារម្ភនោះគឺស្ថានភាពនេះហាក់មិនប្រសើរឡើងនោះទេដោយអ្នកឆ្លើយសំនួរ ២២% បានឆ្លើយជាវិជ្ជមានទៅនឹងសំណួរតែមួយនៅឆ្នាំ២០០។ ជាការបារម្ភដូចគ្នាដែរ ជនរងគ្រោះជាច្រើននាក់យល់ថា អាជ្ញាធរអាចនឹងជួយដល់ពួកគេ ប៉ុន្តែមានជនរងគ្រោះតែ ២% ប៉ុណ្ណោះដែលស្វែងរកការណែនាំផ្លូវច្បាប់ ឬប្តឹងទៅតុលាការ ដែលនេះបង្ហាញពីការខ្វះទំនុកចិត្តលើប្រព័ន្ធតុលាការ។ ចំពោះការលើកឡើងពីប្រពៃណីវិសមភាពដែលស្ត្រីកម្ពុជាបានជួបប្រទះបង្ហាញថា អ្នកឆ្លើយសំណួរជាងពាក់កណ្តាលដែលជាស្ត្រីបានអះអាងថាបុរសដែលវាយដំប្រពន្ធគឺជារឿងធម្មតា។

ជាងនេះទៅទៀត កម្ពុជាគឺជាប្រទេសមួយដែលមានប្រវត្តិអាក្រក់ពាក់ព័ន្ធនឹងការជួញដូរផ្លូវភេទក្នុងពិភពលោកហើយនៅតែជាប្រទេសមួយដែលមានករណីជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទបន្តកើតឡើង។ បើទោះបីជាចំនួនស្ត្រីនិងកុមារដែលត្រូវបានជួញដូរមានការធ្លាក់ចុះជាបន្តបន្ទាប់[39]កម្ពុជានៅតែជា *«ប្រភព ទីកន្លែងឆ្លងកាត់ និងជាគោលដៅដែលបុរស ស្ត្រី និងកុមារប្រឈមនឹងពលកម្មដោយបង្ខំ និងការជួញដូរផ្លូវភេទ»* យោងតាមរបាយការណ៍ស្តីពីការជួញដូរមនុស្សឆ្នាំ២០១៥[40]របស់ក្រសួងការបរទេសអាមេរិក។

---

[38]អង្គការសុខភាពពិភពលោក ការអង្កេតថ្នាក់ជាតិស្តីពីសុខភាព និងបទពិសោធន៍ជីវិតរបស់ស្ត្រីនៅកម្ពុជាខែវិច្ឆិកា ឆ្នាំ២០១៥អាចរកបានតាមរយៈ
<http://www.unwomen.org/~/media/field%20office%20eseasia/docs/publications/2015/11/national%20survey%20on%20womens%20health%20and%20life%20experiences%20in%20cambodia.pdf?v=1&d=20151120T040512>
[39]សលាកប័ត្រសង្ខេបស្តីពីកម្ពុជា ៖ បេសកកម្មស្វែងរកយុត្តិធម៌អន្តរជាតិ អាចរកបានតាមរយៈ ៖
https://www.ijm.org/sites/default/files/download/factsheets/IJM_Factsheet-Cambodia.pdf?v=1.0
[40]របាយការណ៍ស្តីពីការជួញដូរមនុស្សឆ្នាំ២០១៥ អាចរកបានតាមរយៈ ៖
http://www.state.gov/documents/organization/245365.pdf

តថភាពទាំងនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងអនុសាសន៍ដែលដាក់ជូនកម្ពុជាក្នុងអំឡុងពេលនៃការត្រួតពិនិត្យជាសកលនិងតាមពេលវេលាកំណត់វគ្គចុងក្រោយ។ ឧទាហរណ៍ ប្រទេសអេស្ប៉ាញបានកត់សម្គាល់ថា ស្ត្រីដែលរកស៊ីផ្លូវភេទបានប្រឈមនឹងបញ្ហាធ្ងន់ធ្ងរនៅពេលដែលពួកគេស្វែងរកយុត្តិធម៌ ហើយហាក់បីដូចជាទោសករទៅវិញ។ ប្រទេសអ៊ុយរុយហ្គាយបានស្នើឲ្យកម្ពុជាធ្វើវិសោធនកម្ម ឬលុបចោលវប្បធម៌បិតាធិបតេយ្យ និងផ្នត់គំនិតរើសអើងស្ត្រី។ ប្រទេសជាច្រើនដូចជាស្លូវេនី និងប្រេស៊ីល បានស្នើឲ្យកម្ពុជាទម្លាក់ចោលនូវច្បាប់អប់រំដូចជាច្បាប់ស្រីដែលជាច្បាប់ហួសសម័យ និងគ្មានប្រសិទ្ធភាពសម្រាប់ការអនុវត្តរបស់ស្ត្រីដែលជាក់ស្តែងស្ត្រីភាគច្រើនលែងអនុវត្តតាម ប៉ុន្តែទ្រឹស្តីនៅតែមានរហូតដល់ពេលបច្ចុប្បន្ន។

បើទោះបីជាទិន្នន័យនេះគួរឲ្យបារម្ភក៏ដោយ ប៉ុន្តែយោងតាមអង្គការ UN Women[41]គេឃើញមានការវិវឌ្ឍន៍មួយចំនួនពីរាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់សិទ្ធិស្ត្រីដូចជា ការពង្រឹងស្ថាប័នរដ្ឋាភិបាលដើម្បីស្ត្រីមានដូចជា ក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីក្នុងវិស័យអប់រំ ច្បាប់ និងសុខាភិបាល។

ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ បានចែងពីការដាក់ទណ្ឌកម្មទៅលើបទឧក្រិដ្ឋប្រឆាំងនឹងស្ត្រីមានផ្ទៃពោះ ហើយច្បាប់ជាច្រើនផ្សេងទៀតដូចជា ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ និងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការការពារជនរងគ្រោះ បានផ្តល់ការការពារផ្លូវច្បាប់ដល់ស្ត្រីពីអំពើហិង្សាក្នុងគ្រួសារ និងអនុញ្ញាតឲ្យលែងលះដោយមូលហេតុ *«ភាពឃោរឃៅនិងការវាយដំ»។* បញ្ហានេះនៅតែបន្តកើតមាននៅកម្ពុជា ដោយសារពាក់ព័ន្ធនឹងការអនុវត្តច្បាប់ និងការចាប់បង្ខំឲ្យអនុវត្តច្បាប់ ជាក់ស្តែងមាន

---

[41] កម្ពុជា អង្គការ UN WOMEN អាចរកបានតាមរយៈ ៖ http://www.unwomen-eseasia.org/docs/factsheets/01%20CAMBODIA%20factsheet.pdf

ច្បាប់ល្អៗជាច្រើន ប៉ុន្តែមិនមានការចាប់បង្ខំឲ្យអនុវត្តឲ្យបានត្រឹមត្រូវ។ កង្វះចំណេះដឹងផ្នែកច្បាប់ពាក់ព័ន្ធអនក្ខរភាព ការរើសអើងក្នុងការស្វែងរកយុត្តិធម៌ ការផាត់ចេញពីការសម្រេចចិត្ត គឺជាមូលហេតុដែលរារាំងដល់សិទ្ធិរបស់ស្ត្រី។

# ៣. បទពិសោធន៍របស់អ្នកការពារសិទ្ធិមនុស្សស្ត្រីដែលទទួលបានការគាំទ្រពីគម្រោង

អ.ក.ស.ម.ស រងគ្រោះពីការរើសអើងគ្រប់បែបយ៉ាង និងមានសភាពធ្ងន់ធ្ងរ។ ដូច្នេះហើយគេអាចនិយាយបានថា ក្រៅពីមានការឃាយីនិងការគំរាមកំហែងច្រើនពីប្រព័ន្ធតុលាការ អ.ក.ស.ម.ស ប្រឈមនឹងភាពតានតឹង ថប់បារម្ភនិងបញ្ហាសុខភាពផ្លូវចិត្តផ្សេងទៀត។

*"ការដឹកនាំសហគមន៍របស់ខ្ញុំក្នុងជម្លោះដីធ្លីគឺជាកិច្ចការដ៏លំបាក។ ករណីខ្លះ ខ្ញុំមានអារម្មណ៍ថាអស់សង្ឃឹម គ្មានប្រយោជន៍ ក្រៀមក្រំ ភ្លេចភ្លាំង និងពេលខ្លះចង់សម្លាប់ខ្លួនទៀតផង"។*

ដោយ អ.ក.ស.ម.ស (វគ្គបណ្តុះបណ្តាលសុខភាពផ្លូវចិត្ត)

ផ្នែកនេះបង្ហាញពីប្រវត្តិនៃការតស៊ូ និងរឿងរ៉ាវរបស់សកម្មជនដែលទទួលបានការគាំទ្រពីគម្រោង រួមជាមួយនឹងខ្លឹមសារលម្អិតពីប្រភេទនៃការគាំទ្រដែលត្រូវបានផ្តល់ជូនពួកគេ។ ការសម្រេចថាតើសកម្មជនម្នាក់គឺជា អ.ក.ស.ម.ស ឬក៏អត់ ត្រូវបានធ្វើឡើងដោយគណៈកម្មាធិការការពារសេរីភាពមូលដ្ឋាន («គណៈកម្មាធិការ»)បន្ទាប់ពីទទួលបានព័ត៌មានសង្ខេបនៃករណីពីអ្នកដាក់ពាក្យសុំ។ បន្ទាប់មកគម្រោងជាអ្នកសម្រេចពីប្រភេទជំនួយដែលផ្តល់ឲ្យ អ.ក.ស.ម.ស។ គណៈកម្មាធិការមានសមាសភាពបុគ្គលិកក្រៅពី ម.ស.ម.ក និងបុគ្គលិករបស់ ម.ស.ម.ក ម្នាក់ដែលមិនពាក់ព័ន្ធនឹងគម្រោង។ គណៈកម្មាធិការនេះត្រូវបានបង្កើតតាមការកំណត់ក្នុងគោលការណ៍ដែលមានការកំណត់ពីសេណារីយ៉ូនៃការផ្តល់ការគាំទ្រនិងប្រភេទជនរងគ្រោះដែលអាចទទួលបានការគាំទ្រ។ រចនាសម្ព័ន្ធនេះធានានូវភាពមិនលម្អៀងនិងយុត្តិធម៌ខ្ពស់បំផុតក្នុងការធ្វើសេចក្តីសម្រេចចិត្ត។

## ៣.១ ករណីសិក្សា

### *ករណីសិក្សាទី ១ ៖ អ្នកស្រី ហង្ស ចិន្តា អ្នកស្រី ហង្ស សុភា និងអ្នកស្រី ប៉ែន ស៊ីណាត*

ករណីនេះពាក់ព័ន្ធនឹងប្រជាពលរដ្ឋចំនួន ២៤ គ្រួសាររស់នៅក្នុង ភូមិ១ សង្កាត់



៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ហើយក៏ពាក់ព័ន្ធនឹងសិទ្ធិដីធ្លីផងដែរ។ ម.ស.ម.ក បានផ្តល់ជំនួយផ្លូវច្បាប់ដល់ស្ត្រីតំណាងសហគមន៍ទាំងបីនាក់នេះដែលដឹកនាំការតវ៉ាយ៉ាងស្វិតស្វាញជំនួសមុខឲ្យសហគមន៍។ អ.ក.ស.ម.ស គឺអ្នកស្រីហង្ស ចិន្តា អ្នកស្រី ហង្ស សុភា និងអ្នកស្រី ប៉ែន ស៊ីណាត តស៊ូមតិដើម្បីការពារផ្ទៃដីទំហំ ៤២.៧១០ ម៉ែត្រក្រឡារបស់ខ្លួន ដែលពួកគាត់បានកាន់កាប់ចាប់តាំងពីការដួលរលំនៃរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩។

ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ ខេត្តព្រះសីហនុបានឆ្លងកាត់ការអភិវឌ្ឍយ៉ាងលឿន និងមានការកើនឡើងនូវតម្លៃអចលនទ្រព្យ។ ក្នុងឆ្នាំ១៩៩៦ ដីមានទំនាស់នោះត្រូវបានដកហូតដោយអតីតអភិបាលរងទីមួយ ខេត្តព្រះសីហនុ លោក ឃឹម បូ ដែលត្រូវបានចោទថាបានឃុបឃិតជាមួយអាជ្ញាធរពាក់ព័ន្ធដើម្បីទទួលបានកម្មសិទ្ធិលើដីនោះ ហើយបានលក់ទៅឲ្យក្រុមហ៊ុន ថៃ ប៊ុនរ៉ុង។ បន្ទាប់មក ក្រុមហ៊ុនបានពុះដីនោះជាឡូត៍រួចលក់ឲ្យបុគ្គលមានទ្រព្យស្តុកស្តម្ភ យោងតាមការអះអាងរបស់ប្រជាពលរដ្ឋ។ ការដកហូតនេះបានធ្វើឲ្យមានការតវ៉ា និងភាពចលាចលជាច្រើន ហើយនៅឆ្នាំ១៩៩៦ លោក ឃឹម បូ និងកងកម្លាំងចម្រុះប្រដាប់អាវុធរួមមាន នគរបាល និងយោធាបានចុះទៅកាន់ទីតាំងដីមានជម្លោះនោះ។ ពួកគេបានហ៊ុមព័ទ្ធដីនោះ និងបានបាញ់កាំភ្លើងជាច្រើនគ្រាប់ទៅលើអាកាសដើម្បីគំរាម និងបន្លាចប្រជាពលរដ្ឋ។ យោធាបានឃុបឃិតគ្នាឈូសឆាយផលដំណាំនិងផ្ទះសម្បែងរបស់អ្នកភូមិ។ ប្រជាពលរដ្ឋត្រូវបានបង្ខំឲ្យចាកចេញពីភូមិនិងបានបង្ខំចិត្តរស់នៅ

ក្រោមកំណាត់កៅស៊ូតង់។ នៅឆ្នាំ១៩៩៧ ព្រឹត្តិការណ៍ស្រដៀងគ្នានេះបានកើតឡើងជាថ្មី ដោយកម្លាំងកងរាជអាវុធហត្ថបានបំផ្លាញកំណាត់កៅស៊ូតង់របស់ប្រជាពលរដ្ឋទាំងនោះ។ មិនត្រឹមតែប៉ុណ្ណោះ ក្នុងករណីនេះ តំណាងសហគមន៍ម្នាក់គឺអ្នកស្រី ហង្ស ចិន្តា បានរងរបួសធ្ងន់ រីឯអ្នកស្រី មាស សម្បត្តិ អាយុ ៧៧ឆ្នាំ ត្រូវបានចាប់ឃុំខ្លួនក្នុងពន្ធនាគារអស់រយៈពេល ៩ ថ្ងៃ ។ "ការចុះអន្តរាគមន៍" របស់នគរបាល ការរំខាន និងការប៉ះទង្គិចគ្នាបានបន្តកើតមានឡើងរយៈពេលជាច្រើនឆ្នាំ។

នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០២ អ្នកភូមិចំនួន ៩ នាក់ ត្រូវបានចាប់ខ្លួនដាក់ពន្ធនាគាររយៈពេល ២៤ ថ្ងៃ។ អ្នកភូមិទាំងនោះត្រូវបានបង្គាប់ឲ្យផ្តិតមេដៃយល់ព្រមថាពួកគាត់បានកាន់កាប់ដោយខុសច្បាប់លើដីរបស់ក្រុមហ៊ុន។ ទីបំផុតអ្នកភូមិបានយល់ព្រមតាម បន្ទាប់ពីរងការគំរាមថានឹងត្រូវបញ្ជូនទៅកាន់ពន្ធនាគារព្រៃ ស ប្រសិនបើពួកគេបដិសេធ។ ម្យ៉ាងទៀត ដើម្បីទទួលបានការដោះលែង អ្នកភូមិត្រូវបានបង្ខំឲ្យស្នើគ្រួសាររបស់ពួកគេបំផ្លាញផ្ទះសម្បែងរបស់ខ្លួនចោល ដែលនេះជាសំណើមួយដែលគ្រួសារទាំងនោះយល់ព្រមធ្វើតាម។ ការឃាត់តាមប្រព័ន្ធតុលាការនៅតែបន្តកើតមាន ខណៈដែលគ្រួសារទាំងនោះមិនទាន់ទទួលបានលទ្ធផលណាមួយពីបណ្តឹងរបស់ខ្លួននៅឡើយ។

ដោយសារតែបណ្តឹងរបស់ពួកគាត់មិនត្រូវបានអាជ្ញាធរអើពើ ដូច្នោះហើយនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៥ គ្រួសារទាំងនោះបានសម្រេចចិត្តបោះតង់លើដីជម្លោះនោះ។ នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៥ ចៅក្រមសាលាដំបូងខេត្តព្រះសីហនុបានចេញដីកាបង្គាប់ឲ្យគ្រួសាររងគ្រោះទាំងនោះចាកចេញពីដីនោះវិញ។ បន្ទាប់ពីនោះភ្លាម អភិបាលរងខេត្តព្រះសីហនុ ឯកឧត្តម ស៊្រុន ស្រេន បានដឹកនាំកម្លាំងចម្រុះដែលមានយោធានិងនគរបាលចុះទៅកាន់ទីតាំងដីមានជម្លោះនោះហើយបានបំផ្លាញតង់របស់ប្រជាពលរដ្ឋចោល។ គ្រួសាររងគ្រោះនៅតែបន្តប្រឆាំងទៅនឹងដីកាបង្គាប់នោះតាមរយៈប្រព័ន្ធតុលាការ។ គម្រោង អ.ក.ស.ម.ស ផ្តល់ជំនួយដល់ជនរងគ្រោះដោយសារការបណ្តេញចេញជា អ.ក.ស.ម.ស និងគ្រួសាររបស់ពួកគេ។ នៅថ្ងៃទី៦ និង ទី៧ ខែកញ្ញា ឆ្នាំ២០១៥ មេធាវីជាប់

កិច្ចសន្យាម្នាក់របស់ ម.ស.ម.ក បានធ្វើការពិគ្រោះយោបល់ និងសម្ភាសតំណាងរបស់គ្រួសារទាំងនោះ។ នៅថ្ងៃបន្ទាប់ តុលាការបានកោះហៅភាគីទាំងអស់ឲ្យចូលរួមក្នុងសវនាការសួរដេញដោលផ្ទាល់មាត់តាមពាក្យបណ្ដឹងរបស់សហដើមចោទដែលជំទាស់នឹងដីកាបង្គាប់របស់តុលាការកាលពីខែមេសា ឆ្នាំ២០១៥។ ម.ស.ម.ក សង្ឃឹមថាការទាមទាររបស់សហគមន៍នឹងបានសម្រេចហើយសិទ្ធិរបស់ពួកគាត់នឹងត្រូវបានគេទទួលស្គាល់តាមរយៈជំនួយពីមេធាវីវិជ្ជាជីវៈនៃគម្រោង អ.ក.ស.ម.ស ។

## *ករណីសិក្សាទី ២ ៖ ក្រុមហ៊ុន ប៊ិញហឿក ១ ខេត្តមណ្ឌលគិរី*

ចំពោះករណីទី ២ នេះ ម.ស.ម.ក បានផ្ដល់ជំនួយផ្លូវច្បាប់ និងហិរញ្ញវត្ថុដល់សហគមន៍ក្នុងភូមិចក់ចារ ឃុំស្រែឈូក ស្រុកកែវសីម៉ា ខេត្តមណ្ឌលគិរី។ ជនរងគ្រោះភាគច្រើនក្នុងករណីនេះគឺជាជនជាតិពូនង។ អ្នកភូមិបានប្រាប់ថា ពួកគេបានកាន់កាប់ដីមានជម្លោះនេះតាំងពីទសវត្សរ៍ឆ្នាំ១៩៤០។ គ្រួសារពលរដ្ឋក្នុងភូមិចក់ចារ ពឹងផ្អែកលើការងារផ្នែកកសិកម្មដើម្បីទ្រទ្រង់ជីវភាពបង្កបង្កើនផលស្រូវ និងកាត់វល្លិ ព្រមទាំងប្រមូលជ័រឈើមានតម្លៃ និងអនុផលព្រៃឈើផ្សេងទៀតតាមទំនៀមទម្លាប់ជាច្រើនជំនាន់មកហើយ។ ក្រៅពីការផ្ដល់ប្រភពសម្រាប់ទ្រទ្រង់ជីវភាពរបស់សហគមន៍ដីនិងព្រៃនៅតំបន់នោះក៏មានកន្លែងគោរពសក្ការៈ និងជាព្រៃដូនតារបស់អ្នកភូមិ ដែលជាទីផ្សាភ្ជាប់ទៅនឹងដូនតានិងព្រលឹងធម្មជាតិដែលមានទំនាក់ទំនងបង្កើតបានជាផ្នែកដ៏សំខាន់នៃអត្តសញ្ញាណវប្បធម៌ និងភាពសុខដុមរមនារបស់សហគមន៍ផងដែរ។

នៅឆ្នាំ២០១៣ ក្រុមហ៊ុន ប៊ិញហឿក១ “Binh Phuoc One” ដែលទទួលបានដីសម្បទានសេដ្ឋកិច្ច បានឈូសឆាយដីធ្លីរបស់អ្នកភូមិទំហំ ១.០០០ ហិកតាក្នុងភូមិចក់ចារដោយគ្មានការពិគ្រោះយោបល់ ទោះបីជាមានការរារាំងពីអ្នកភូមិយ៉ាងណាក៏ដោយ។ តាំងពីពេលនោះមក អ្នកភូមិបានស្វះស្វែងរកកិច្ចអន្តរាគមន៍ពីអាជ្ញាធររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនានា ប៉ុន្តែជម្លោះនេះមិនត្រូវបានដោះស្រាយឡើយ ហើយក្រុមហ៊ុនបានបន្តឈូសឆាយដីនិងព្រៃនោះដដែល។ នៅខែកុម្ភៈ ឆ្នាំ២០១៤ គណៈកម្មការសិទ្ធិ

មនុស្សបានទទួលពាក្យបណ្តឹងពីសកម្មជន ដំណាលគ្នានឹងរដ្ឋសភានិងព្រឹទ្ធសភាដែរ។ ដោយឡែក សហគមន៍បានដាក់ញត្តិជូនទៅអភិបាលខេត្តដោយស្នើឲ្យមានអន្តរាគមន៍ក្នុងករណីនេះ។ សកម្មភាពទាំងនេះមិនទទួលបានជោគជ័យឡើយ ដូច្នេះហើយបានជាពេលខ្លះអ្នកភូមិបានព្យាយាមការពារដីធ្លីដោយខ្លួនឯង។

ខណៈដែលក្រុមហ៊ុនកំពុងឈូសឆាយដីធ្លីនៅដើមខែធ្នូ ឆ្នាំ២០១៤ អ្នកភូមិបានប្រមូលផ្តុំគ្នាបញ្ឈប់សកម្មភាពនោះ។ រយៈពេលពីរបីថ្ងៃក្រោយមក តំណាងអ្នកភូមិបានប្រមូលឯកសារ និងស្នាមមេដៃរបស់អ្នកភូមិដើម្បីស្នើសុំអន្តរាគមន៍ពីអង្គការមិនមែនរដ្ឋាភិបាលនិងស្ថាប័នរដ្ឋាភិបាល។ ខណៈពេលធ្វើដំណើរពីភូមិទៅកាន់ទីរួមខេត្ត បុរសគ្មានអត្តសញ្ញាណ ៥ នាក់ ពាក់ម៉ាសបិទមុខ បានចុះមកភូមិដោយមានកាំភ្លើងមកជាមួយផងបានស្វែងរកតំណាងសហគមន៍ទាំងនោះ។ បន្ទាប់មក នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ សកម្មជន ៦ នាក់ ត្រូវបានតុលាការកោះហៅដើម្បីសាកសួរ ប៉ុន្តែពួកគេបានស្នើព្រះរាជអាជ្ញាពន្យារពេលនៃការសាកសួរ ព្រោះពុំទាន់មានតំណាងផ្លូវច្បាប់។ សហចុងចោទទាំង ៦ នាក់នោះរួមមានលោក ប្រប់ ដឹប លោក យ៉ាន ម៉ៅ អ្នកស្រី ស្រួច ថាវ អ្នកស្រី ប្រប់ សុខា លោក នួន រីម និងអ្នកស្រី ខៀវ ចន្ថា ក្នុងនោះមានស្ត្រី ៣ នាក់ផងដែរ។ ពួកគេត្រូវបានកោះហៅជាថ្មីនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥។ ម.ស.ម.ក បានធ្វើអន្តរាគមន៍នៅដំណាក់កាលនេះ ដោយផ្តល់ជំនួយមេធាវីការពារក្តីជូនសកម្មជន លោក យ៉ាន ម៉ៅ។ ជំនួយនេះត្រូវបានផ្តល់ជូនដោយគម្រោងការពារសេរីភាពមូលដ្ឋាន។

នៅខែកុម្ភៈ ឆ្នាំ២០១៥ ព្រះរាជអាជ្ញាបានកោះហៅសកម្មជន ៦ នាក់ដើម្បីសាកសួរពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទ "ហិង្សាលើអចលនទ្រព្យ" ប៉ុន្តែមិនបានឃុំខ្លួនពួកគេឡើយ។ មេធាវីបានដាក់សំណើកុំឲ្យព្រះរាជអាជ្ញាចាត់វិធានការលើករណីនេះ ដោយបញ្ជាក់ថានេះគ្រាន់តែជាករណីរដ្ឋប្បវេណីប៉ុណ្ណោះ។ នៅថ្ងៃទី២២ ដល់ថ្ងៃទី២៤ ខែមិនា ឆ្នាំ២០១៥ មេធាវីបាន អ.ក.ស.ម ទៅតទល់នៅចំពោះមុខចៅក្រមស៊ើប សួរ។ ក្រោយមក នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥ មេធាវីបានសម្ភាសកូនក្តីនៅក្រៅពន្ធនាគារ។

នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥ មេធាវីបានអមកូនក្តីចូលរួមក្នុងសវនាការនៅចំពោះមុខចៅក្រមស៊ើបសួរ ស្រាប់តែនៅថ្ងៃនោះ ចៅក្រមស៊ើបសួរបានបង្គាប់ឲ្យឃុំខ្លួនសកម្មជនទាំង ៦ នាក់ដាក់ពន្ធនាគារខេត្តមណ្ឌលគីរីតែម្តង។ នៅខែឧសភា ឆ្នាំ២០១៥ មេធាវីជាប់កិច្ចសន្យារបស់ ម.ស.ម.ក បានសម្ភាសកូនក្តីគឺលោក យ៉ាន ម៉ៅ ក្នុងពន្ធនាគារខេត្តមណ្ឌលគីរី និងបានសម្ភាសសាក្សី ៨ នាក់ទៀត។ នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៥ មេធាវីការពារក្តីបានដាក់សំណើទៅកាន់សាលាឧទ្ធរណ៍ដើម្បីស្នើសុំឲ្យកូនក្តីខ្លួនស្ថិតនៅក្រៅឃុំបន្ទាប់ពីសាលាដំបូងខេត្តបានបដិសេធលើសំណើនេះ។ បន្ទាប់មក មេធាវីការពារក្តីបានប្រជុំជាមួយមេធាវីជាន់ខ្ពស់របស់ ម.ស.ម.ក ដើម្បីរកយុទ្ធសាស្ត្រក្នុងការការពារកូនក្តី។ នៅថ្ងៃទី៣០ ខែកក្កដា មេធាវីការពារក្តីបានស្នើឲ្យតុលាការដោះលែងកូនក្តីគឺ លោក យ៉ាន ម៉ៅ ជាបណ្តោះអាសន្នសិន។ នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៥ មេធាវីការពារក្តី គឺលោក ជា សុភី បានចុះទៅខេត្តមណ្ឌលគីរីដើម្បីជួបជាមួយលោក យ៉ាន ម៉ៅ ហើយនៅថ្ងៃទី៧ ខែសីហា លោក យ៉ាន ម៉ៅ ត្រូវបានតុលាការសម្រេចដោះលែងឲ្យនៅក្រៅឃុំ។

នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៥ គម្រោងបានសម្រេចផ្តល់ជំនួយផ្លូវច្បាប់ដល់ អ.ក.ស.ម ៤ នាក់ផ្សេងទៀតដែលជាប់ពាក់ព័ន្ធក្នុងទំនាស់ដីធ្លីនេះ។ ពួកគេក៏ជាជនជាតិពូនងនៅភូមិចក់ចារ ស្រុកកែវសីម៉ា ខេត្តមណ្ឌលគីរីដែរ។

### *ករណីសិក្សាទី ៣ ៖ អ្នកស្រី ផាវ ញ៉ឹង ខេត្តកោះកុង*

អ្នកស្រី ផាវ ញ៉ឹង គឺជាតំណាងសហគមន៍ដីធ្លីក្នុងភូមិព្រែកជីក ឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង។ ដីធ្លីប្រជាពលរដ្ឋប្រមាណ ៧៥ គ្រួសាររស់នៅក្នុងភូមិព្រែកជីកត្រូវបានកាន់កាប់ដោយក្រុមហ៊ុនឯកជនមួយ។ ប្រជាពលរដ្ឋ ៣១ គ្រួសារ បានជាប់គាំងក្នុងទំនាស់ដីធ្លីដ៏ជូចត់មួយជាមួយម្ចាស់ក្រុមហ៊ុនអភិវឌ្ឍ ដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ។

នៅខែតុលា ឆ្នាំ២០០៤ អ្នកស្រី ផាវ ញ៉ឹង និងគ្រួសាររបស់គាត់បានសម្រេចចិត្តទិញដីមួយកន្លែងដែលមានទំហំ ៤០ គុណនឹង ៣០០ ម៉ែត្រក្នុងតម្លៃ ៤០០ ដុល្លារសហរដ្ឋអាមេរិកពីបុរសម្នាក់ឈ្មោះ ណក ហៀង ដែលរស់នៅលើដីនោះតាំងពីឆ្នាំ១៩៩៥។ បន្ទាប់ពីទទួលបានដី គ្រួសាររបស់គាត់បានសង់ផ្ទះ និងដាំដើមស្វាយ។



នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៧ បុរសម្នាក់ឈ្មោះ សុខ ហុង បានចុះមកកាន់ដីនោះដោយមានកម្មករចំនួន ៣០ នាក់ និងកងកម្លាំងចម្រុះ ៣០ នាក់រួមមាន ប៉ូលីស និងកងរាជអាវុធហត្ថ។ ពួកគេព្យាយាមបំផ្លាញផ្ទះ និងឈូសឆាយដីស្រែទំហំ ៩០ ហិចតា ដោយធ្វើឲ្យប៉ះពាល់ដល់ប្រជាជន ៣១ គ្រួសារ និងផ្ទះ ៦ ខ្នងទៀតផង។ តែយ៉ាងណាពួកគេកម្ទេចផ្ទះបានត្រឹមតែ ៣ ខ្នងប៉ុណ្ណោះ ដោយសារតែការតវ៉ារបស់អ្នកភូមិដែលរងផលប៉ះពាល់ដឹកនាំដោយអ្នកស្រី ផាវ ញ៉ឹង។ ការកម្ទេចផ្ទះនោះ ធ្វើឡើងទៅតាមដីកាបង្គាប់របស់តុលាការខេត្តកោះកុង ដែលបានចេញសាលក្រមគាំទ្រលោក សុខ ហុង ក្នុងការបណ្តេញប្រជាជន ៣១ គ្រួសារ និងកម្ទេចផ្ទះរបស់ពួកគេ។ ក្នុងសាលក្រមនោះ បានចោទប្រកាន់អ្នកភូមិទាំងនោះថា បានកាន់កាប់ដោយខុសច្បាប់លើដីរបស់អ្នកដទៃដែលមានប័ណ្ណកម្មសិទ្ធិ ប៉ុន្តែសេចក្តីសម្រេចនោះមិនដែលបានបង្ហាញដល់អ្នកភូមិរងការប៉ះពាល់ទាំងនោះឡើយ។ បន្ទាប់ពីមានការប៉ុនប៉ងបណ្តេញចេញ អ្នកស្រី ផាវ ញ៉ឹង ត្រូវបានគ្រួសារដែលរងការប៉ះពាល់ទាំងអស់ស្នើឲ្យធ្វើជាតំណាង និងដឹកនាំការការពារដីធ្លីរបស់ពួកគេ។

ភាគីម្ខាងទៀត គឺលោក ហេង ហ៊ុយ (ម្ចាស់ក្រុមហ៊ុន ហេង ហ៊ុយ អេហ្គ្រីខលឈ័រ គ្រុប) បាននាំយកកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃសាលដីការបស់តុលាការកំពូលមកកាន់អ្នកភូមិ នៅចុងខែសីហា ឆ្នាំ២០០៩ ដោយបានបង្ហាញថា លោកបានឈ្នះ

ក្ដីលោក សុខ ហុង និងអះអាងថាគាត់ជាអ្នកកាន់កាប់ដីនោះ។ តែយ៉ាងណា ម.ស.ម.ក បានពិនិត្យមើលនិងបានផ្ទៀងផ្ទាត់សាលដីការដែលប្រគល់ដីឲ្យទៅលោក ហេង ហ៊ុយ ពិតជាមិនបានរាប់បញ្ចូលភូមិព្រែកជីកទេ។ នៅអំឡុងខែកញ្ញា និងខែតុលា ឆ្នាំ២០០៩ លោក ហេង ហ៊ុយ អមដំណើរដោយនគរបាលប្រដាប់ដោយអាវុធ និងមន្ត្រីរាជអាវុធហត្ថ បានត្រឡប់មកកាន់ដីទំនាស់វិញនិងបានបណ្ដេញអ្នកភូមិ ។ អ្នកភូមិបានដាក់ពាក្យបណ្ដឹងទៅរដ្ឋសភា ព្រឹទ្ធសភា ក្រសួងមហាផ្ទៃនិងតុលាការ ប៉ុន្តែមិនទទួលបានផលអ្វីឡើយ។ ជាលទ្ធផលនៃកិច្ចព្រមព្រៀងនោះ បាននាំឲ្យអ្នកភូមិបោះបង់ដីធ្លីរបស់ខ្លួនជាច្រើន ប៉ុន្តែពួកគេយល់ថាគ្មានជម្រើសអ្វីក្រៅពីទទួលយកឡើយ។ ជាការពិត អ្នកភូមិត្រូវបានគេប្រាប់ថាដីធ្លីរបស់ពួកគាត់ទាំងអស់នឹងត្រូវដកហូតយក ប្រសិនបើមិនយល់ព្រមធ្វើតាមទេនោះ។ លោក ហេង ហ៊ុយ មិនបានគោរពតាមកិច្ចព្រមព្រៀងជាពាក្យសម្ដីឡើយ ហើយគាត់បានបន្តប្រើប្រាស់គ្រឿងចក្រឈូសឆាយដីមានជម្លោះនោះ និងមិនបានប្រឹងប្រែងជួយដល់អ្នកភូមិឲ្យទទួលបានប័ណ្ណកម្មសិទ្ធិលើដីធ្លីដែលនៅសល់ឡើយ។ ជាលទ្ធផល ប្រជាជន ២៤ គ្រួសារ (ក្នុងចំណោម ៣១ គ្រួសារ) បានបដិសេធកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុន ដោយពួកគេនិយាយថា វាធ្វើឡើងដោយការបង្ខិតបង្ខំ។ បន្ទាប់ពីការដាក់ពាក្យបណ្ដឹងព្រហ្មទណ្ឌរបស់លោក ហេង ហ៊ុយ ប្ដឹងអ្នកស្រី ផាវ ញ៉ឹង អ្នកស្រីក៏ត្រូវបានតុលាការកោះហៅដើម្បីសួរចម្លើយដោយព្រះរាជអាជ្ញាតុលាការខេត្តកោះកុង កាលពីថ្ងៃទី១ ខែឧសភា ឆ្នាំ ២០១០។ អ្នកស្រីត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើហិង្សាលើម្ចាស់អចលនទ្រព្យ ប៉ុន្តែ ៣ ខែ ក្រោយមក ការចោទប្រកាន់នេះត្រូវបានទម្លាក់ចោលនៅពេលអ្នកស្រីយល់ព្រមកាត់ដីខ្លះឲ្យលោក ហេង ហ៊ុយ។

នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣ អ្នកភូមិរងផលប៉ះពាល់ ៩ នាក់ រួមទាំង អ្នកស្រី ផាវ ញ៉ឹង បានបញ្ជាក់ក្នុងលិខិតផ្ញើជូនអភិបាលខេត្តកោះកុង ពីបំណងធ្វើអត្តឃាតនៅមុខតុលាការកំពូល ប្រសិនបើករណីនេះមិនត្រូវបានដោះស្រាយទេនោះ។ ពួកគេបានផ្ដិតមេដៃលើឯកសារនោះដែលបញ្ជាក់ថាដោយសារតែការឃុបឃិតគ្នារបស់អាជ្ញាធរ (ដូចជា

មេឃុំជីខក្រោម មេឃុំជីខលើ មន្ត្រីសុរិយោដីស្រុកស្រែអំបិល និងសមាជិកតុលាការ) អ្នកភូមិបានមកដល់ផ្លូវទាល់ច្រកហើយ។ ពួកគេបានបញ្ជាក់ថា *"ចុងបិចរបស់តុលាការជាអាវុធសម្លាប់ប្រជាជន។*

នៅថ្ងៃដដែលនោះ ក្រុមដែលមានសមាជិក ៤ នាក់ រួមទាំង អ្នកស្រី ផាវ ញ៉ឹង បានដាក់ពាក្យបណ្ដឹងទៅតុលាការខេត្តកោះកុងដោយស្នើមោឃភាពកិច្ចសន្យាជាមួយលោក ហេង ហ៊ុយ ដោយសំអាងថា ពួកគេត្រូវបានបំភិតបំភ័យ និងបង្ខំឲ្យចុះកិច្ចសន្យានោះ។ ដើមបណ្ដឹងទាំង ៤ នាក់ត្រូវបានកោះហៅឲ្យបង្ហាញខ្លួនក្នុងតុលាការនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣ និងជាថ្មីម្ដងទៀតនៅថ្ងៃទី១០ ខែមិនា ឆ្នាំ២០១៥ ដើម្បីបង្ហាញទឡ្ហីករណ៍ផ្ទាល់មាត់។ បន្ទាប់មក ពួកគេត្រូវបានកោះហៅឲ្យបង្ហាញខ្លួនក្នុងសវនាការនៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ និងរង់ចាំសាលក្រមរបស់តុលាការ។

ក្នុងនាមជាសកម្មជនដែលតស៊ូយ៉ាងសកម្ម ដើម្បីទាមទារសិទ្ធិរបស់សហគមន៍ក្នុងជម្លោះដីធ្លីដ៏ជូរចត់ អ្នកស្រី ផាវ ញ៉ឹង និងគ្រួសាររបស់គាត់បានទទួលរងការគំរាមកំហែងជាបន្តបន្ទាប់ពីអាជ្ញាធរមូលដ្ឋាន និងប៉ូលីស និងប្រឈមនឹងការយាយីតាមប្រព័ន្ធតុលាការ។ នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៤ ពោលគឺរយៈពេលពីរបីថ្ងៃបន្ទាប់ពីអ្នកស្រី ផាវ ញ៉ឹង បានដាក់ពាក្យបណ្ដឹងស្នើឲ្យចាត់ទុកកិច្ចព្រមព្រៀងដីធ្លីនោះជាមោឃៈ ក្រុមហ៊ុនកសិកម្ម ហេង ហ៊ុយ គ្រុប បានដាក់ពាក្យបណ្ដឹងទៅតុលាការខេត្តកោះកុងដោយចោទប្រកាន់អ្នកស្រី ផាវ ញ៉ឹង ថាបានសម្លាប់គោពីរក្បាលរបស់ក្រុមហ៊ុន។ អ្នកស្រី ផាវ ញ៉ឹង ត្រូវបានកោះហៅទៅសួរចម្លើយនៅសាលាដំបូងខេត្តកោះកុងកាលពីថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៤ និងត្រូវបានដោះលែងនៅថ្ងៃដដែលក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ជាថ្មីម្ដងទៀត អ្នកស្រី ផាវ ញ៉ឹង ត្រូវបានកោះហៅនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៥ ប៉ុន្តែក្រោយមកត្រូវបានសម្រេចឲ្យរួចខ្លួននៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥។ ក្នុងការជំនុំជម្រះក្ដីចុងក្រោយនេះ ម.ស.ម.ក បានផ្ដល់ជំនួយផ្លូវច្បាប់តាមរយៈមេធាវីជាប់កិច្ចសន្យា។ នៅខែវិច្ឆិកា ឆ្នាំ២០១៥ គណៈកម្មាធិការបានសម្រេចទទួលយករឿងក្ដីនៃ អ.ក.ស.ម.ស

ចំនួន ៦ នាក់ផ្សេងទៀតដែលជាប់ពាក់ព័ន្ធក្នុងជម្លោះដីធ្លីនោះ ហើយគម្រោងបានផ្តល់ជំនួយផ្លូវច្បាប់ដល់ពួកគេ។

### *ករណីសិក្សាទី ៤ ៖ អ្នកស្រី អ៊ុំ សុភី ខេត្តកំពង់ឆ្នាំង*



អ្នកស្រី អ៊ុំ សុភី គឺជាសកម្មជនដីធ្លីនៅក្នុងភូមិឡពាង ខេត្តកំពង់ឆ្នាំង។ អ្នកស្រីបានទៅរស់នៅទីនោះក្នុងឆ្នាំ២០០៤ ជាមួយស្វាមីអ្នកស្រីដែលបានរស់នៅទីនោះតាំងពីឆ្នាំ១៩៩៣ មកម្ល៉េះ។ អស់រយៈពេលជាច្រើនឆ្នាំមកហើយ អ្នកស្រីបានខិតខំប្រឹងប្រែងឈានមុខក្នុងការងារសហគមន៍ ដើម្បីបញ្ឈប់ការទិញដី សហគមន៍ពីសំណាក់ក្រុមហ៊ុន ខេ ឌី ស៊ី របស់លោកស្រី ជា ខេង ភរិយារបស់រដ្ឋមន្ត្រីក្រសួងធនធានរ៉ែនិងថាមពល លោក ស៊ុយ សែម ។ ដោយសារតែសកម្មភាពនេះ អ្នកស្រីបានទទួលរងផលលំបាកជាច្រើន។ ក្នុងនាមជាអ្នកដឹកនាំសហគមន៍ដើម្បីតវ៉ាជំទាស់ទៅនឹងការទន្ទ្រានយកដីធ្លី អ្នកស្រីបានប្រឈមការគំរាមកំហែងជាច្រើនយ៉ាងពីសំណាក់អាជ្ញាធរមូលដ្ឋាន និងនគរបាលព្រមទាំងការឃាយឃីតាមប្រព័ន្ធតុលាការ។

ភាពតានតឹងបានចាប់ផ្តើមក្នុងឆ្នាំ១៩៩៦ នៅពេលដែលអ្នកភូមិត្រូវបានបង្ខិតបង្ខំឲ្យលក់ដីរបស់ខ្លួន។ ក្នុងអំឡុងពេលនោះ ប្រធានភូមិបានប្រាប់ពួកគាត់ថា ប្រសិនបើពួកគាត់លក់ដី ពួកគាត់នឹងទទួលបានប្រាក់ ប៉ុន្តែប្រសិនបើមិនព្រមលក់ទេ អ្នកភូមិនឹងបាត់បង់ដីដោយមិនទទួលបានសំណងអ្វីឡើយ។ គ្រួសារមួយចំនួនបានយល់ព្រមលក់ដី ចំណែកគ្រួសារមួយចំនួនទៀតមិនព្រមលក់ឡើយ។ ក្នុងឆ្នាំ២០០៧ ក្រុមហ៊ុន KDC បានដាក់ពាក្យបណ្តឹងប្រឆាំងនឹងម្ចាស់ដីចំនួន ១៤ គ្រួសារ ពីបទរស់នៅដោយខុសច្បាប់លើដីរបស់ក្រុមហ៊ុន ហើយនៅថ្ងៃទី៩ ខែមករា ឆ្នាំ២០០៨ កម្មកររបស់ក្រុមហ៊ុន KDC បានប្រើ

ប្រាស់គ្រឿងចក្រឈូសឆាយបំផ្លិចបំផ្លាញផ្ទះសម្បែង និងហ៊ុមព័ទ្ធដីស្រែដោយពុំមានការជូនដំណឹងជាមុន ។ ផ្ទះមួយខ្នងនិងដីស្រែមួយចំនួនរបស់អ្នកស្រីក៏ត្រូវបានបំផ្លិចបំផ្លាញផងដែរ។ អ្នកស្រីបានរស់នៅទីនោះ និងបានដាំស្វាយ ធ្វើស្រែ ដាំដើមខ្នុរ និងដើមដូងដើម្បីបំពេញបន្ថែមប្រាក់ចំណូលរបស់អ្នកស្រីក្រៅពីអាជីពជាគ្រូបង្រៀន។

ដោយសារតែអ្នកស្រីបានដឹកនាំសហគមន៍ ប្រឆាំងតតាំងនឹងសកម្មភាពទន្ទ្រានយកដីធ្លី អ្នកស្រី អ៊ុំ សុភី ត្រូវបានបញ្ជូនមកសួរចម្លើយនៅតុលាការខេត្តក្រោមការចោទប្រកាន់ពីបទញុះញង់។ សំណុំរឿងរបស់អ្នកស្រីត្រូវបានបញ្ជូនទៅកាន់សាលាដំបូងរាជធានីភ្នំពេញ ហើយដោយសារតែបារម្ភពីការចាប់ខ្លួន អ្នកស្រីបានគេចខ្លួនទៅកាន់ប្រទេសថៃមួយរយៈដោយមិនត្រឡប់មកប្រទេសកម្ពុជាវិញរហូតដល់ខែធ្នូ ឆ្នាំ២០១១។ នៅពេលត្រឡប់មកវិញ អ្នកស្រីទទួលបានដំណឹងក្រៅផ្លូវការពីសាច់ញាតិរបស់អ្នកស្រី ដោយប្រាប់មិនឲ្យចូលរួមក្នុងការតវ៉ាទៀតឡើយ ពុំដូច្នោះទេអ្នកស្រីនឹងត្រូវអាជ្ញាធរចាប់ខ្លួន។ ក្រោយមកទៀត មានលិខិតអនាមិកមួយសន្លឹកបិទលើជញ្ជាំងផ្ទះអ្នកស្រី ដោយបានសរសេរគំរាមកំហែងអ្នកស្រី និងស្វាមីអ្នកស្រីដែលមានខ្លឹមសារថា ប្រសិនបើអ្នកស្រីតវ៉ា អ្នកស្រីនឹងត្រូវចាប់ខ្លួនឬសម្លាប់ចោល។ នៅក្នុងសំបុត្រនោះ ក៏មានគូសរូបភាពកាំភ្លើងផងដែរ។ ទោះបីជាមានហានិភ័យយ៉ាងណាក៏ដោយ អ្នកស្រីនៅតែបន្តការតវ៉ាដោយយកលិខិតនោះទៅកាន់តុលាការខេត្តកំពង់ឆ្នាំង និងបានដាក់ពាក្យបណ្តឹង។ មិនមានការកំណត់អត្តសញ្ញាណជនល្មើសឡើយ ប៉ុន្តែអធិការនគរបាលស្រុកបានកោះហៅអ្នកស្រីមកសាកសួរដើម្បីស៊ើបអង្កេត។

បន្ទាប់ពីសម្រេចចិត្តដាក់ពាក្យបណ្តឹងទៅថ្នាក់ជាតិ អ្នកភូមិបានចាប់ផ្តើមហែរក្បួនឆ្ពោះទៅកាន់រាជធានីភ្នំពេញនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៤ ប៉ុន្តែពួកគាត់ត្រូវបានរារាំងនិងបង្ក្រាបយ៉ាងហិង្សាពីសំណាក់កងកម្លាំងនគរបាល។ អ្នកភូមិជាច្រើនបានរងរបួស ចំណែកស្វាមីរបស់អ្នកស្រី អ៊ុំ សុភី គឺលោក ងួន ញឿន ត្រូវបានចាប់ខ្លួនជាមួយនឹងអ្នកភូមិពីរនាក់ផ្សេងទៀត។ លោក ងួន ញឿន បានបញ្ជាក់ថា លោកត្រូវបានគេវាយដំក្នុងពេល

ចាប់ខ្លួននោះ។ ទោះបីជាមានបញ្ហាទាំងនេះក៏ដោយ ក៏អ្នកស្រី អ៊ុំ សុភី នៅតែបន្តដឹកនាំការហែក្បួនឆ្ពោះទៅកាន់រាជធានីភ្នំពេញដើម្បីទាមទារឲ្យមានដំណោះស្រាយក្នុងករណីទំនាស់នេះ និងទាមទារឲ្យដោះលែងស្វាមីរបស់អ្នកស្រី និងអ្នកភូមិដែលត្រូវបានចាប់ខ្លួនផ្សេងទៀត។ អ្នកទាំងនោះត្រូវបានដោះលែងវិញនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤។ ទោះបីជាមានការផ្ដល់ដំណឹងពីការធានារបស់គណៈកម្មការសិទ្ធិមនុស្សរដ្ឋសភាថានឹងរកដំណោះស្រាយក្នុងករណីទំនាស់នេះ ហើយសមាជិកគណៈកម្មការរដ្ឋសភាលោក ជា ប៉ូច បានចុះបេសកកម្មទៅកាន់តំបន់ទំនាស់នោះកាលពីខែមករា ឆ្នាំ២០១៥ ប៉ុន្តែជម្លោះនោះនៅតែមិនអាចដោះស្រាយបាននៅឡើយ។

ថ្មីៗនេះ អ្នកស្រី អ៊ុំ សុភី មានការបារម្ភកាន់តែខ្លាំងនិងមានអារម្មណ៍ខ្វាយខ្វល់ពីសុវត្ថិភាពផ្ទាល់ខ្លួន និងគ្រួសារ ជាពិសេសនៅពេលអ្នកស្រីធ្វើការតស៊ូមតិដើម្បីសហគមន៍។

## *ករណីសិក្សាទី ៥ ៖ អ្នកស្រី ប្រាយ នីម សហគមន៍ថ្មគោល* (SOS) *រាជធានីភ្នំពេញ*

អ្នកស្រី ប្រាយ នីម ជាតំណាងសហគមន៍ថ្មគោល អ្នកស្រីតែងតែដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំសហគមន៍អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ("សហគមន៍ SOS") ដែលនៅជិតអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ ដោយសារតែរដ្ឋាភិបាលបានអភិវឌ្ឍនៅតំបន់ជុំវិញអាកាសយានដ្ឋាន អ្នកស្រី នីម និងអ្នកភូមិផ្សេងទៀតបានប្រឈមនឹងបញ្ហាជាច្រើន ដោយសារទទួលបានដំណឹងថាផ្ទះរបស់ពួកគាត់




នឹងត្រូវបានរុះរើចោលដើម្បីពង្រីកផ្លូវតំបន់ទ្រនាប់អាកាសយានដ្ឋានក្នុងឆ្នាំ២០១២។ អ្នកស្រី នីម និងអ្នកភូមិផ្សេងទៀតបានព្យាយាមស្វែងរកអន្តរាគមន៍ជាច្រើនលើកច្រើនសារពីស្ថាប័នពាក់ព័ន្ធរួមទាំងខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន។ កាលពីខែវិច្ឆិកា ឆ្នាំ ២០១២ សហគមន៍បានប្រើប្រាស់វិធីសាស្ត្រថ្មីមួយដើម្បីទាក់ទាញការយកចិត្តទុកដាក់ពី

សាធារណៈជនលើបញ្ហារបស់ពួកខ្លួន។ ពួកគាត់បានសរសេរអក្សរ “S.O.S” លើដំបូលផ្ទះ ដើម្បីស្វាគមន៍ប្រធានាធិបតីលោក បារ៉ាក់ អូបាម៉ា (Barack Obama) ដែលធ្វើទស្សនកិច្ចមកកាន់ប្រទេសកម្ពុជាក្នុងអំឡុងកិច្ចប្រជុំកំពូលអាស៊ាន។ យ៉ាងណាក៏ដោយ ពីរបីម៉ោងក្រោយមក កងកម្លាំងនគរបាលបានចុះមកបញ្ឈប់ការសរសេរអក្សរទាំងនោះ។ នៅថ្ងៃដដែលនោះ អ្នកស្រី នីម និងអ្នកភូមិ ៧នាក់ផ្សេងទៀតត្រូវបានចាប់ខ្លួន។

កាលពីឆ្នាំ២០១៤ នៅពេលដែលសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្វើដំណើរទៅចូលរួមកិច្ចប្រជុំកំពូលអាស៊ានក្នុងប្រទេសមីយ៉ាន់ម៉ា អ្នកភូមិក៏បានព្យាយាមសរសេរអក្សរ “S.O.S” ម្តងទៀតលើដំបូលផ្ទះរបស់ពួកគាត់ ដោយមានទាំងបិទរូបថតរបស់សម្តេចនាយករដ្ឋមន្ត្រីនិងភរិយាសម្តេចក្នុងគោលបំណងស្វែងរកការអន្តរាគមន៍។ ពីរបីម៉ោងក្រោយមក កងរក្សាសន្តិសុខខណ្ឌមួយក្រុមបានចុះមកលុបអក្សរ “S.O.S” វិញ ។ ក្នុងនាមជាតំណាងសហគមន៍ដែលជំទាស់ទៅនឹងសកម្មភាពបណ្តេញចេញទាំងបង្ខំ និងការផ្តល់សំណងមិនសមរម្យ អ្នកស្រី នីម តែងទទួលរងការគំរាមកំហែងជាច្រើនលើកច្រើនសារពីសំណាក់អាជ្ញាធរ។ ដោយសារតែមូលហេតុទាំងនេះហើយទើបអ្នកស្រី នីម មានបញ្ហាតានតឹងខ្លាំងនិងបញ្ហាផ្លូវចិត្តជាច្រើនទៀតផង។

## ៣.២ ចម្រៀង

ក្នុងអំឡុងពេលវគ្គបណ្តុះបណ្តាលដែលរៀបចំឡើងដោយគម្រោង អ.ក.ស.ម.ស អ.ក.ស.ម.ស ជាច្រើនដែលទទួលបានការគាំទ្រពីគម្រោងបានច្រៀងចម្រៀងស្តីពីការតវ៉ាចំនួនពីរបទដែលឆ្លុះបញ្ចាំងពីបទពិសោធន៍របស់សហគមន៍ដូចខាងក្រោម ៖

### ឯណាទៅសិទ្ធិខ្ញុំ?

I. ឆ្នាំ៧៩ យើងបានផុតទុក្ខ
រស់នៅសុខសាន្តគ្រប់ទីកន្លែង
រស់មានក្តីសុខឥតព្រួយចំបែង
ទាំងគេទាំងឯងនៅក្នុងគ្រួសារ។

II. ឆ្នាំ៩៦ យើងជួបបញ្ហា
ព្រោះគ្មានដីកាបង្គាប់ឲ្យចេញ
ប្រើកងកម្លាំងរុះរើបណ្តេញ
បង្ខំឲ្យចេញ និងចាប់ដាក់គុក។

III. ផ្ទះខ្ញុំដីខ្ញុំពិតប្រាកដជាក់ ហេតុអ្វីក៏អ្នកចោទឥតកោតក្រែង
លបលួចបន្លំធ្វើប្លង់គ្នាឯង រួចស្រែកក្តែងៗថាឯងជាម្ចាស់។

IV. យកដីពួកខ្ញុំលក់ឲ្យក្រុមហ៊ុន វិស័យឯកជនដែលមានឈ្មោះថា
ថៃ ប៊ុនរ៉ុង នោះសែនល្អពិរោះ ការពិតវិញនោះវាសែនឫស្យា។

V. លោកតុលាការស្តាប់ឲ្យបានច្បាស់ ពួកខ្ញុំជាម្ចាស់លើដីនេះពិត
មិនមែនមុសាឬក៏ប្រឌិត សូមលោកពិនិត្យកុំលំអៀងឡើយ។

VI. លោកតុលាការពិនិត្យឲ្យបានច្បាស់ កុំយកក្រដាសបំភ្លៃការពិត
ពួកខ្ញុំម្ចាស់ដីមិនមែនប្រឌិត នេះជាការពិតឥតមុសាឡើយ។

## តុលាការខ្ញុំ

I. ពួកយើងសហគមន៍ជួបជុំតវ៉ា រឿងតុលាការអយុត្តិធម៌
ធ្វើខុសប្រសាសន៍របស់រដ្ឋា អាងសិទ្ធិដីកាចាប់យើងដាក់គុក
(បន្ទរ) អាងសិទ្ធិ អាជ្ញាចោទថាខុសច្បាប់។

II. ដោយគេចោទថានិយាយមិនពិត ឬក៏ជំរិតឆបោកគេឯង
រំលោភលើអចលនអ្នកផ្សេង ឬពួកអ្នកឯងបំផ្លាញទ្រព្យគេ
(បន្ទរ) គឺពួកអ្នកឯងត្រូវតែមានទោស។

III. ការពិតពួកយើងការពារសិទ្ធិសោះ ម្តេចចាប់ដាក់ខ្នោះដោយគ្មានមេត្តា
កុំអាងអំណាចព្រោះតែដុល្លា លោកតុលាការត្រូវយុត្តិធម៌
(បន្ទរ) លោកតុលាការត្រូវយុត្តិធម៌។

IV. ពួកយើងសហគមន៍មិនចង់បានអ្វី ពីសិទ្ធិសេរីដីផ្ទះខ្លួនឯង
ហើយក៏មិនចង់ទៅកន្លែងផ្សេង យើងខ្មែរគ្នាឯងត្រូវអាណិតផង
(បន្ទរ) ឲ្យខ្មែរគ្នាឯងរស់បានសុខផង។

# ៤. សេចក្ដីសន្និដ្ឋាននិងអនុសាសន៍

អ.ក.ស.ម.ស បានប្រឈមនឹងការគំរាមកំហែង និងបញ្ហាជាច្រើនក្នុងប្រទេសកម្ពុជា។ ការគាបសង្កត់ មិនឲ្យធ្វើបាតុកម្មដោយសន្តិវិធីមានកាន់តែច្រើនឡើង និងការបំបិតសំឡេងជំទាស់កំពុងធ្វើឲ្យ អ.ក.ស.ម ប្រឈមនឹងស្ថានភាពកាន់តែអាក្រក់ ហើយការគំរាមកំហែងទាំងនេះកាន់តែមានលក្ខណៈធ្ងន់ធ្ងរចំពោះស្ត្រី ដោយសារបរិបទនៃការរើសអើងយេនឌ័រនិងវប្បធម៌មិនស្មើភាព។ ការធ្វើទុក្ខបុកម្នេញ ការឃាឃីតាមប្រព័ន្ធតុលាការ ការដាក់ពន្ធនាគារ និងការគំរាមកំហែងលើ អ.ក.ស.ម.ស បានបង្កផលប៉ះពាល់ច្រើនដោយស្មានមិនដល់ ហើយព្រឹត្តិការណ៍ទាំងនេះក៏អាចប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពផ្លូវចិត្តរបស់ជនរងគ្រោះជា អ.ក.ស.ម.ស ផងដែរ។ ការធ្វើការងារឥតឈប់ឈរ និងការលះបង់របស់ អ.ក.ស.ម.ស សម្រាប់សហគមន៍របស់ខ្លួនគួរតែបានការទទួលស្គាល់ពីសំណាក់រដ្ឋាភិបាលកម្ពុជា សង្គមស៊ីវិលនិងសង្គមទាំងមូល។ ប្រការសំខាន់នោះ ត្រូវបញ្ជ្រាបទស្សនវិស័យយេនឌ័រនៅគ្រប់សកម្មភាពទាំងអស់របស់ស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនឹង អ.ក.ស.ម។ សកម្មភាពដែលអនុវត្តដោយគម្រោង អ.ក.ស.ម.ស របស់ ម.ស.ម.ក បានបង្ហាញថាដំណើរការនេះពិតជាមានសារៈសំខាន់ដើម្បីបង្កើនការយល់ដឹងឲ្យបានត្រឹមត្រូវពីសម្ពាធដែល អ.ក.ស.ម.ស បានជួបប្រទះ។

នៅក្នុងកំណត់ត្រាសង្ខេបនេះ ម.ស.ម.ក បានបង្ហាញពីការវាយតម្លៃលើស្ថានភាពរបស់ អ.ក.ស.ម.ស នៅឆ្នាំ២០១៥។ ការទទួលស្គាល់ផលលំបាក និងការរើសអើងយេនឌ័រក្នុងប្រទេសកម្ពុជានិងហានិភ័យនិងបញ្ហាប្រឈមក្នុងការបំពេញការងាររបស់ អ.ក.ស.ម.ស ដែលអាចឈានទៅរកភាពតានតឹង ការថប់បារម្ភ និងបញ្ហាផ្លូវចិត្ត ហើយ ម.ស.ម.ក សូមគូសបញ្ជាក់ឡើងវិញអំពីអនុសាសន៍ដែលបានចងក្រងក្នុងកំណត់ត្រាសង្ខេបនេះ

និងបន្ថែមអនុសាសន៍មួយចំនួនទៀតសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសពាក់ព័ន្ធនឹង អ.ក.ស.ម.ស ដែលអនុសាសន៍ទាំងនោះរួមមាន ៖

- *ទទួលស្គាល់នូវតម្រូវការការពារជាក់លាក់របស់ក្រុមអ្នកការពារសិទ្ធិមនុស្សដូចជា អ.ក.ស.ម.ស ដែលពាក់ព័ន្ធនឹងបញ្ហាក្នុងជីវិតឯកជនរបស់ពួកគេ។*
- *ជំរុញឲ្យមានកម្មវិធីជាក់លាក់ដែលប្រឆាំងនឹងការរើសអើងភេទចំពោះ អ.ក.ស.ម.ស។*
- *ផ្តល់ការទទួលស្គាល់ជាផ្លូវច្បាប់ និងនយោបាយដល់ការងាររបស់ អ.ក.ស.ម.ស។*
- *បង្កើតយន្តការនិងកម្មវិធីការពារថ្នាក់ជាតិសម្រាប់ អ.ក.ស.ម.ស ដែលប្រឈមនិងហានិភ័យ។*
- *ដាក់បញ្ចូលក្នុងកម្មវិធីអប់រំដែលផ្តោតលើការលុបបំបាត់រចនាសម្ព័ន្ធនៃអំពើហិង្សា និងការរើសអើងប្រឆាំងនឹងស្ត្រី និងវិសមភាពសេដ្ឋកិច្ចសង្គមផ្អែកតាមយេនឌ័រ។*
- *ជៀសវាងក្នុងការត្រូវប្រើប្រាស់ភាសាអសុរោះ ឬរើសអើងទៅលើ អ.ក.ស.ម.ស និងស្ត្រីទូទៅ។*
- *ធានាការគោរពសិទ្ធិសេរីភាពក្នុងការជួបប្រជុំ ហើយបញ្ឈប់ជាផ្លូវការនូវការហាមប្រាមតាមអំពើចិត្តទាំងស្រុងចំពោះការជួបប្រជុំជាសាធារណៈ។*
- *បញ្ឈប់នូវការអនុវត្តដែលបង្ខំឲ្យ អ.ក.ស.ម ចុះហត្ថលេខាលើកិច្ចសន្យា ដែលមានការរឹតត្បិតដល់សិទ្ធិរបស់ពួកគេដើម្បីជាថ្នូរទៅនឹងការដោះលែង ឬចៀសវាងការចោទប្រកាន់ ព្រមទាំងលុបចោលនូវលិខិតទាំងឡាយណាដែលបានចុះហត្ថលេខានាពេលកន្លងមក។*
- *អនុវត្តជាបន្ទាន់នូវការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិសម្រាប់ប្រទេសកម្ពុជាឲ្យស្របទៅតាមគោលការណ៍ទីក្រុងប៉ារីស។*

- *បញ្ឈប់ការយាយីតាមប្រព័ន្ធតុលាការទៅលើ អ.ក.ស.ម សកម្មជននយោបាយ និងអ្នកនយោបាយបក្សជំទាស់ ព្រមទាំងដោះលែងជាបន្ទាន់ដោយគ្មានលក្ខខណ្ឌដល់អ្នកកំពុងជាប់ឃុំដែលត្រូវបានចោទប្រកាន់ ផ្តន្ទាទោសដោយសារហេតុផលនយោបាយ។*
- *ឆ្លើយតបជាវិជ្ជមានចំពោះសំណើរបស់អ្នករាយការណ៍ពិសេសអំពីស្ថានភាព អ.ក.ស.ម. នៅក្នុងដំណើរទស្សនកិច្ចផ្លូវរដ្ឋ (នៅឆ្នាំ២០១២ អ្នករាយការណ៍ពិសេសបានសរសេរសំណើមកកាន់រាជរដ្ឋាភិបាលដើម្បីមកធ្វើទស្សកិច្ចផ្លូវរដ្ឋនៅកម្ពុជា[42] )។*

ក្រៅពីនេះ ម.ស.ម.ក សូមលើកអនុសាសន៍ខាងក្រោមសម្រាប់អង្គការសង្គមស៊ីវិល និងស្ថាប័នអន្តរជាតិដែលធ្វើការជាមួយស្ត្រីនិង អ.ក.ស.ម នៅកម្ពុជា ៖

- *លើកកម្ពស់ការបញ្ជ្រាបយេនឌ័រតាមស្ថាប័នដោយបង្កើតគោលនយោបាយសមភាពយេនឌ័រ ដែលអនុវត្តចំពោះកម្មវិធី និងនីតិវិធីផ្ទៃក្នុង។*
- *រៀបចំការបណ្តុះបណ្តាលអំពីរំញោចយេនឌ័រសម្រាប់បុគ្គលិកទាំងអស់ដើម្បីបង្កើនការយល់ដឹងពីបញ្ហារបស់ អ.ក.ស.ម.ស និងស្ត្រីទូទៅនៅកម្ពុជា។*
- *ផ្តល់វគ្គបណ្តុះបណ្តាលអំពីយេនឌ័រសម្រាប់មេធាវីដែលការពារក្តីឲ្យ អ.ក.ស.ម.ស។*
- *ណែនាំពីទស្សនវិស័យយេនឌ័រដល់ការងារតស៊ូមតិដែលអនុវត្តក្នុងនាម អ.ក.ស.ម ។*

[42]អង្គការសហប្រជាជាតិ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស "ការចុះតាមប្រទេស" http://goo.gl/Z1SD0r